

# ការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងវិស័យសេដ្ឋកិច្ចនៅកម្ពុជា

MICRO RAINBOW INTERNATIONAL FOUNDATION

apcom.org
Equity. Dignity. Social Justice.

VOICE

# មាតិកា


១. សេចក្តីថ្លែងអំណរគុណ 1
២. របាយការណ៍សង្ខេប 2
៣. សេចក្តីផ្តើម 6

- ហេតុផលនៃរបាយការណ៍ និងជំហានបន្ទាប់ 6
- វិធីសាស្ត្រនៃការស្រាវជ្រាវ និងការពិភាក្សាក្រុម 7
- វិសាលភាព និងដែនកំណត់នៃរបាយការណ៍នេះ 8
- និយមន័យ និងពាក្យ 8

៤. បរិបទសិទ្ធិមនុស្សបច្ចុប្បន្ន និងការជះឥទ្ធិពលលើ
អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា 10
៥. បទពិសោធន៍ជីវិតៈ ការផាត់ចេញអ្នកស្រឡាញ់ភេទដូចគ្នា
ក្នុងវិស័យសេដ្ឋកិច្ច នៅកម្ពុជា 15

- ការងារ សហគ្រិនភាព និងសេវាកម្មហិរញ្ញវត្ថុ 18
- ការអប់រំ 19
- សុខភាព 22

៦. សេចក្តីសន្និដ្ឋាន 24
៧. អនុសាសន៍ 27
៨. ឯកសារយោង 29

# ១.សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះគឺជាផ្នែកមួយរបស់ ហ្វាយណិនអ៊ីន[1](Finance Inc) គឺជាគម្រោងមានរយៈពេលបីឆ្នាំ (២០១៨-២០២០) មានគោលបំណងដើម្បីផ្សារភ្ជាប់ស្ថាប័នហិរញ្ញវត្ថុដែលផ្តោតលើការអភិវឌ្ឍអន្តរជាតិ ក៏ដូចជាវិស័យឯកជនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច ដើម្បីដាក់បញ្ចូលសិទ្ធិ កង្វល់ និងសក្តានុពលរបស់អ្នកស្រឡាញ់ភេទដូចគ្នាកាន់តែច្រើន។ ក្រៅពីការស្រាវជ្រាវនេះ មានសកម្មភាពផ្សេងទៀតរបស់គម្រោងដូចជា ការស្វែងរកការគាំទ្រ ការកសាងភាពជាដៃគូ និងការកសាងសមត្ថភាព ដែលអនុវត្តន៍ដោយ អេបខម (Apcom) និងអង្គការដៃគូនៅក្នុងប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ឡាវ និងហ្វីលីពីន។របាយការណ៍នេះត្រូវបានរៀបចំជាផ្នែកមួយនៃរបាយការណ៍បួនដែលមានចំណងជើងថា "ការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាក្នុងវិស័យសេដ្ឋកិច្ច"។ របាយការណ៍នេះផ្តោតលើ បទពិសោធន៍របស់សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងការដាក់បញ្ចូលក្នុងវិស័យសេដ្ឋកិច្ច និងសង្គម៖ ការពេញចិត្តរបស់ពួកគេអំពីសិទ្ធិការងារ ការទទួលសេវា និងធនធានហិរញ្ញវត្ថុ ការអប់រំ និងសុខភាព។ របាយការណ៍ត្រូវបានស្រាវជ្រាវក្នុងប្រទេសចំនួន៤ នៅអាស៊ីអាគ្នេយ៍រួមមាន ប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ឡាវ និងហ្វីលីពីន។

របាយការណ៍នេះរៀបចំដោយ អេបខម (Apcom[2]) ដោយសហការជាមួយអង្គការដៃគូក្នុងប្រទេសទាំង៤នេះ។ របាយការណ៍នៅប្រទេសកម្ពុជានេះអនុវត្តដោយ មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF[3]) ចាប់ពីខែកក្កដា ដល់ តុលា ឆ្នាំ២០១៩។ អេបខម (Apcom) សូមថ្លែងអំណរគុណ លូកាស ប៉ាអូលី បូរាហី (Lucas Paoli Itaborahy) ជាអ្នកនិពន្ធនិងសម្របសម្រួល លោក គង់ យ៉ារ៉ា និងកញ្ញា ឈឿង រចនា ជាអ្នកសម្របសម្រួល ក្រុមពិភាក្សា និង អ៊ីរីន ផៅវិល (Erin Power) ជាអ្នកកែសម្រួលពាក្យពេចន៍។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួមពិភាក្សាក្រុមទាំង ៣២នាក់ ដែលបានចំណាយពេលវេលាចែករំលែកនូវចំណេះដឹង និងបទពិសោធន៍។ យើងអរគុណជាខ្លាំងដែលពួកគាត់បានចែករំលែកអំពីរឿងរ៉ាវ អារម្មណ៍ បញ្ហាប្រឈមផ្ទាល់ខ្លួន និងភាពទូទៅនៃការប្រឈមមុខនឹងការមាក់ងាយ និងការរើសអើងដោយសារតែនិន្នាការភេទ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ។ ទាំងអស់នេះហើយគឺជាបទពិសោធន៍រស់នៅជាក់ស្តែង និងសំឡេងផ្ទាល់របស់អ្នកចូលរួម ដែលជាចំណុចស្នូលនៃរបាយការណ៍នេះ ហើយនិងបានដាក់ចេញនូវអនុសាសន៍មួយចំនួនធំផងដែរ។ ការចូលរួមរបស់ពួកគាត់គឺមានសារៈសំខាន់ខ្លាំងបំផុត ហើយសង្ឃឹមថានឹងចូលរួមជាចំណែកក្នុងការធ្វើឱ្យប្រសើរឡើង នូវជីវិតអ្នកស្រឡាញ់ភេទដូចគ្នាកម្ពុជាលើសពីអ្វីដែលមានក្នុងរបាយការណ៍នេះ។

អេបខម (Apcom) សូមថ្លែងអំណរគុណផងដែរចំពោះម្ចាស់ជំនួយ វ៉យ (Voice[4]) ដែលឧបត្ថម្ភគម្រោងហ្វាយណិនអ៊ីន (Finance Inc. project[5]) ក្នុងកិច្ចការស្រាវជ្រាវនេះ។

អេបខម (Apcom) និងមូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) មានការទទួលខុសត្រូវរួមចំពោះមាតិកា រួមទាំងកំហុសឆ្គងដោយប្រការណាមួយ។

---

[1]APCOM (2018). Finance Inc: Developing an LGBTQI Inclusive Approach for the Asian Development Bank. At: https://www.apcom.org/storage/2018/12/Compass-Series-Finance-Inc-rev-2-10122018.pdf

[2]APCOM: https://www.apcom.org/

[3]Micro Rainbow International Foundation: https://mrifoundation.global/

[4] Voice, an initiative by the Netherlands Ministry of Foreign Affairs, is an innovative grant facility that supports the most marginalised and discriminated people in ten countries in Africa and Asia. It aims to amplify and connect thus far unheard voices in efforts to leave no one behind. At: https://voice.global/

[5] APCOM (2018). Finance Inc: Developing an LGBTQI Inclusive Approach for the Asian Development Bank. At: https://www.apcom.org/storage/2018/12/Compass-Series-Finance-Inc-rev-2-10122018.pdf

## ២. របាយការណ៍សង្ខេប

របាយការណ៍នេះអនុវត្តចាប់ពីខែកក្កដា ដល់ខែតុលា ឆ្នាំ២០១៩។ មូលនិធិមីក្រូឥន្ទធនូអន្តរជាតិនៅកម្ពុជាបានស្រាវជ្រាវ ហើយវិភាគប្រភពបន្ទាប់បន្សំ និងអនុវត្តស៊ីជម្រៅលើការពិភាក្សាក្រុមជាមួយអ្នកស្រឡាញ់ភេទដូចគ្នាចំនួន ៣២នាក់។

លទ្ធផលរបាយការណ៍នេះ មានគោលបំណងបង្ហាញទិដ្ឋភាពទូទៅអំពីសិទ្ធិមនុស្សនៃអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ដែលត្រូវបានគេរៀបចំ និងលើកស្ទួយឡើង ឧបសគ្គបច្ចុប្បន្ន និងឱកាសនៃការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសង្គម សេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ។ អ្នកចូលរួមផ្ទាល់ទាំង ៣២នាក់ ដែលរងផលប៉ះពាល់ដោយសារគោលនយោបាយ ការអនុវត្ត ឥរិយាបថ និងអាកប្បកិរិយា ពួកគាត់បានផ្តល់រូបភាពលម្អិតអំពីបទពិសោធន៍រស់នៅឧបសគ្គដែលបានជួបប្រទះ ក៏ដូចជាការលើកកម្ពស់ជីវភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងការលើកស្ទួយសក្តានុពលពេញលេញ រួមទាំងការផ្តល់យោបល់របស់ពួកគេសម្រាប់ការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ន។

ខណៈពេលដែលយើងទទួលស្គាល់វិសាលភាពនៃការស្រាវជ្រាវនៅមានកំណត់ និងចង់បញ្ជាក់ឱ្យច្បាស់ថាការស្រាវជ្រាវនេះមិនបានអះអាងទូលំទូលាយ ហើយក៏មិនបង្ហាញរូបភាពពេញលេញនៃស្ថានភាពទាំងស្រុងរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាដែរ។ យើងជឿជាក់ថារបាយការណ៍នេះគឺមានភ័ស្តុតាងសំខាន់ៗនៃឧបសគ្គបច្ចុប្បន្ន និងឱកាសសម្រាប់លើកស្ទួយការដាក់បញ្ចូលក្នុងវិស័យសេដ្ឋកិច្ចរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ នៅពេលបញ្ចូលលទ្ធផលការស្រាវជ្រាវពីមុន រួមទាំងរបាយការណ៍ស្រាវជ្រាវឆ្នាំ ២០១៨ *"ការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាក្នុងវិស័យសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍៖ ការស្រាវជ្រាវនៅប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ឡាវ និងហ្វីលីពីន"* 6 ក៏ដូចជារបាយការណ៍ប្រទេស ៣ បន្ថែមទៀតនៃប្រទេសឥណ្ឌូនេស៊ី ឡាវ និងហ្វីលីពីន លំនាំមួយលេចចេញមក ដែលគួរតែត្រូវបានរកឃើញយ៉ាងល្អិតល្អន់ជាងមុន ដោយធ្វើការបង្កើតទិន្នន័យ ក៏ដូចជាការស្រាវជ្រាវបែបគុណភាព និងបែបបរិមាណឱ្យកាន់តែស៊ីជម្រៅ។

### ស្ថានភាពសិទ្ធិមនុស្សសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាមានភាពប្រសើរឡើង តែឧបសគ្គជាច្រើននៅតែមាន

អ្នកចូលរួមពិភាក្សាក្រុមទាំង ៣២នាក់ បានទទួលស្គាល់ថាស្ថានភាពទូទៅនៃអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា មានភាពប្រសើរឡើងច្រើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ រដ្ឋាភិបាលកម្ពុជាចាប់ផ្តើមបង្ហាញការគាំទ្រ និងមានសញ្ញាវិជ្ជមានលើការអនុវត្ត (UPR) ជុំទី៣ ដែលទាក់ទងនឹងការត្រួតពិនិត្យបញ្ហាសិទ្ធិមនុស្សគ្រប់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ រួមមានស្ថានភាពសិទ្ធិមនុស្សនៃជនជាតិភាគតិច ដែលក្នុងនោះរួមមានអ្នកស្រឡាញ់ភេទដូចគ្នា7 ដោយរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ ២០១៩ បានទទួលយកអនុសាសន៍ចំនួន ៩ ដែលទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណ ឬការបង្ហាញយេនឌ័រ។8 បន្ថែមពីនេះទៀតចំនួនអង្គការ ម្ចាស់ជំនួយ និងសម្ព័ន្ធមិត្តមានការកើនឡើង និងបច្ចុប្បន្នមានព័ត៌មានវិជ្ជមានច្រើនអំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងមានមនុស្សកាន់តែច្រើនឡើងៗហាក់ដូចជាកំពុងចេញមុខជាអ្នកស្រឡាញ់ភេទដូចគ្នា។ ទន្ទឹមនឹងនេះក៏នៅតែមានអំពើហឹង្សា និងការរើសអើងជាច្រើនកើតឡើងជារៀងរាល់ថ្ងៃចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា និងសង្គមដែលផ្តោតលើបទដ្ឋានយេនឌ័រគោលពីរ (ប្រុស និងស្រី) និងការស្រឡាញ់ភេទផ្ទុយគ្នាតែម៉្យាងក្នុងគ្រួសារ ដែលរារាំងមនុស្សពីការយល់ដឹងអោយបានកាន់តែច្បាស់អំពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា។

[6] https://nf3y0lqssvfx.cdn.shift8web.com/wp-content/uploads/2020/10/Report_Economic-Inclusive_v5.pdf

[7] For more information on the outcome of the UPR, see letter dated 19 August 2019 from the UN High Commissioner for Human Rights, Michelle Bachelet, to the Cambodian Minister of Foreign Affairs and International Cooperation, H.E. Mr. Prak Sohkhonn. At:https://lib.ohchr.org/HRBodies/UPR/Documents/Session32/KH/HC_letter_Cambodia_ENG.pdf

[8] United Nations Human Rights Council. (2019). Universal Periodic Review (UPR) (Third Cycle), 2019: Cambodia. Matrix of recommendations (English). At https://www.ohchr.org/EN/HRBodies/UPR/Pages/KHindex.aspx

**ទម្រង់នៃអំពើហិង្សា និងការរើសអើងទូទៅភាគច្រើនដែលអ្នកចូលរួមបានជួបប្រទះមានដូចជា៖**

- ការរើសអើងពីក្រុមគ្រួសារ សហគមន៍ និងអជ្ញាធរមូលដ្ឋានមួយចំនួន
- ខ្វះយន្តការរាយការណ៍ពីអំពើហិង្សា និងការរើសអើង
- ខ្វះការគាំទ្រពីអជ្ញាធរមូលដ្ឋាន
- មិនទាន់មានច្បាប់ការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា
- ការបកស្រាយខុស និងការយល់ច្រឡំពីអត្តសញ្ញាណអ្នកស្រឡាញ់ភេទដូចគ្នាដោយសង្គមជាទូទៅ។ ដូចដែលបានលើកឡើងពីអ្នកចូលរួមជាច្រើននាក់ថា៖ *"ពួកយើង គឺជាព្រាយបិសាចក្នុងផ្នត់គំនិតប្រជាជនកម្ពុជា"*

ភស្តុតាងដែលប្រមូលបានតាមរយៈចម្លើយរបស់អ្នកចូលរួមទាំង ៣២នាក់ គឺទាក់ទងទៅនឹងការស្រាវជ្រាវពីមុន ក៏ដូចជាបច្ចុប្បន្ន និងសង្កត់ធ្ងន់ទៅលើលំនាំនៃការរើសអើងដែលបានឆ្លងកាត់ដោយប្រជាជនស្រឡាញ់ភេដូចគ្នាកម្ពុជា។

**អ្នកចូលរួមបានរាយការណ៍អំពីការរងទុក្ខបុកម្និញជាហូរហែដូចជា៖**

- ពីគ្រួសារ និងសហគមន៍របស់ពួកគេ
- នៅសាលារៀន
- នៅក្នុងកន្លែងធ្វើការ
- នៅឯមណ្ឌលសុខភាព
- ពីស្ថាប័នហិរញ្ញវត្ថុ

ការរើសអើងគ្រប់ស្រទាប់ទាំងអស់នេះ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមិនត្រឹមតែចំពោះសុខភាពផ្លូវចិត្ត និងរាងកាយរបស់អ្នកស្រឡាញ់ភេទដូចគ្នាប៉ុណ្ណោះទេ តែក៏ប៉ះពាល់ដល់ការអប់រំ និងជំនាញវិជ្ជាជីវៈ ហើយទាំងនេះគឺធ្វើឱ្យអន្តរាយដល់ឱកាសនៃការលើកកម្ពស់ជីវភាព ការរួចផុតពីភាពក្រីក្រ និងការទទួលបានសក្តានុពលពេញលេញរបស់ពួកគេ។

**បទពិសោធន៍រស់នៅ៖ ការផាត់ចេញអ្នកស្រឡាញ់ភេទដូចគ្នាពីវិស័យសេដ្ឋកិច្ចនៅកម្ពុជា**
**ការងារ សហគ្រិនភាព និងសេវាកម្មហិរញ្ញវត្ថុ**

អ្នកចូលរួមបានរាយការណ៍ជាឯកច្ឆន្ទថា អត្តសញ្ញាណជាអ្នកស្រឡាញ់ភេទដូចគ្នារបស់ពួកគេ ជាទូទៅបញ្ឈប់ពួកគេពីការស្វែងរក ឬរក្សាការងារ។ និយោជក និងអ្នករួមការងារហាក់ដូចជាមិនគោរពនូវទំនោរផ្លូវភេទ អត្តសញ្ញាណ ឬការបង្ហាញយេនឌ័ររបស់ពួកគេទេ ហើយពួកគេច្រើនតែរងគ្រោះដោយសារការជេរប្រមាថមើលងាយ ការបៀតបៀនរំខាន និងការរំលោភបំពាននៅកន្លែងធ្វើការ។ លើសពីនេះទៅទៀតអ្នកចូលរួមជាច្រើនបាននិយាយថា ការឈប់ពីការសិក្សាលឿនរបស់ពួកគេ បានបញ្ឈប់ពួកគេពីការទទួលបានចំណេះដឹង និងជំនាញចាំបាច់ដើម្បីទទួលបានការងារល្អប្រសើរ។ អ្នកចូលរួមទាំងអស់បានបង្ហាញពីបំណងចង់បើកអាជីវកម្មខ្នាតតូចផ្ទាល់ខ្លួន ដែលជាមធ្យោបាយមួយផ្សេងទៀតក្នុងការរកប្រាក់ចំណូល ប៉ុន្តែពួកគេកម្រមានធនធានហិរញ្ញវត្ថុដើម្បីធ្វើបែបហ្នឹងណាស់។

ភាពលំបាកផ្នែកហិរញ្ញវត្ថុ គឺជាតថភាពទូទៅសម្រាប់អ្នកចូលរួមទាំងអស់ ដោយសារតែភាពក្រីក្រ និងការរើសអើង។ អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ស្ថិតជាប់នៅក្នុងវដ្តនៃភាពក្រីក្រ ដោយសារតែការរើសអើងពីគ្រួសារ នៅក្នុងសាលារៀន និងនៅកន្លែងធ្វើការរបស់ពួកគេ ដូច្នេះហើយមិនអាចបំពេញការចំណាយក្នុងការរស់នៅ

របស់ពួកគេបានទេ។ លើសពីនេះទៀតអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) មិនអាចទទួលបានសេវាកម្មធនាគារទេ ពីព្រោះពួកគេមិនមានឯកសារចាំបាច់គ្រប់គ្រាន់ ឬមិនមានអ្នកណាម្នាក់ធានា។

## ការអប់រំ និងសុខភាព

អ្នកចូលរួមទាំងអស់បានទទួលរងនូវការសម្លុតមាក់ងាយ គំរាមកំហែង និងការរើសអើងនៅក្នុងពេលខ្លះនៅឯសាលារៀនពីសំណាក់គ្រូ ឬសិស្ស ឬទាំងពីរ ដោយលើកឡើងថាសាលារៀនក្នុងប្រទេសកម្ពុជាមិនផ្តល់កន្លែងទំនេរ និងមានសុវត្ថិភាពសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាទេ។ បរិយាកាសអរិភាពជាញឹកញាប់នេះ បានបង្ខំមនុស្សទាំងនោះឱ្យបោះបង់ការសិក្សា ដែលបណ្តាលឱ្យពួកគេមានជីវភាពក្រីក្រ និងការលំបាកផ្នែកហិរញ្ញវត្ថុ។ ក្នុងករណីខ្លះការបដិសេធរបស់ក្រុមគ្រួសារក៏នាំឱ្យខ្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលជាលទ្ធផលបានធ្វើឱ្យអន្តរាយដល់ឱកាសរបស់យុវជនស្រឡាញ់ភេទដូចគ្នា (LGBTQI) ក្នុងការទទួលបានការអប់រំកម្រិតខ្ពស់ផងដែរ។

បទពិសោធន៍របស់អ្នកចូលរួម នៅក្នុងមូលដ្ឋានសុខាភិបាលក៏មានបញ្ហា និងប្រឈមផងដែរ។ អ្នកចូលរួមទាំងអស់ ហាក់ដូចជាចែករំលែកនូវអារម្មណ៍នៃការមិនទុកចិត្តចំពោះអ្នកជំនាញសុខភាពសាធារណៈ ពីព្រោះពួកគេច្រើនតែមិនមានសមត្ថភាពគ្រប់គ្រាន់ ឬមិនមានសមត្ថភាពសោះ ឬមិនទទួលបានការបណ្តុះបណ្តាល ដើម្បីផ្តល់ការព្យាបាលជាក់លាក់ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។ ដោយសារតែកម្រិតនៃភាពក្រីក្រ គឺវាមិនទំនងដែលថាអ្នកស្រលាញ់ភេទដូចគ្នា អាចមានលទ្ធភាពថែទាំសុខភាពពីខាងសេវាឯកជនបានទេ។

## អនុសាសន៍

ប្រទេសនីមួយៗបានរាយការណ៍ និងផ្តល់អនុសាសន៍ទៅរដ្ឋាភិបាល វិស័យឯកជន និងអង្គការធ្វើលើបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា។ APCOM និង MRIF រួមជាមួយដៃគូនានានឹងបន្តធ្វើការតស៊ូមតិ ដើម្បីទទួលបានការអនុវត្តនូវអនុសាសន៍ទាំងអស់នេះ ក្នុងគោលបំណងដើម្បីលុបចោលនូវរចនាសម្ព័ន្ធ និងឧបសគ្គផ្សេងៗទៀតសម្រាប់ការដាក់បញ្ចូលផ្នែកសេដ្ឋកិច្ច ក៏ដូចជាផ្នែកសង្គម និងទទួលបានការចូលរួមយ៉ាងពេញលេញសម្រាប់ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) នៅក្នុងសង្គមកម្ពុជា។



កិច្ចពិភាក្សាក្រុមនៅរាជធានីភ្នំពេញ

អនុសាសន៍ទាំងនេះអំពាវនាវឱ្យមានការអនុម័ត និងការអនុវត្តទៅលើគោលនយោបាយនៃការដាក់បញ្ចូលការអនុវត្តជាក់ស្តែង និងកម្មវិធីផ្សេងៗ។ បទពិសោធន៍រស់នៅជាក់ស្តែង និងការចែករំលែកផ្ទាល់ចេញពីអ្នកស្រឡាញ់ភេទដូចគ្នាដ៏ក្លាហានទាំង ៣២រូប ដែលហ៊ាននិយាយចេញមក និងបានស្ម័គ្រចិត្តចំណាយពេលវេលា ចំណេះដឹង និងបទពិសោធន៍របស់ពួកគេនៃការផាត់ចេញពីវិស័យសេដ្ឋកិច្ចនៅកម្ពុជា និងបានផ្តល់នូវអនុសាសន៍ជាច្រើន។ ខាងក្រោមនេះគឺជាអនុសាសន៍មួយចំនួន ដើម្បីមើលអនុសាសន៍ទាំងស្រុង សូមចូលទៅកាន់ទំព័រ ២៥-២៧។

១. រដ្ឋាភិបាលគួរតែអនុវត្តនូវអនុសាសន៍ចំនួន ៩ ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណ ឬការបង្ហាញយេនឌ័រ នៅក្នុងការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់ជុំទី៣ (UPR- Third Cycle) ក្នុងឆ្នាំ ២០១៩ របស់អង្គការសហប្រជាជាតិ។ នេះរួមបញ្ចូលទាំងការដាក់ចេញនូវច្បាប់ប្រឆាំងនឹងការរើសអើង ដែលធានានូវភាពស្មើគ្នា និងហាមឃាត់ជាក់លាក់ចំពោះការរើសអើងគ្រប់ប្រភេទ រាប់បញ្ចូលទាំងមូលដ្ឋានសាសនា និន្នាការភេទ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ ឬលក្ខណៈផ្លូវភេទ។ ហើយក៏រួមបញ្ចូលទាំងការអនុម័តនូវវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីប្រឆាំងនឹងការរើសអើង និងអំពើហឹង្សាគ្រប់រូបភាពចំពោះប្រជាពលរដ្ឋដោយសារតែនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ និងនាំខ្លួនជនល្មើសដើម្បីភាពយុត្តិធម៌។

២. គ្រូបង្រៀន អ្នកផ្តល់សេវាផ្នែកសុខាភិបាល អាជ្ញាធរមូលដ្ឋាន និយោជក និងអ្នកផ្តល់សេវាហិរញ្ញវត្ថុគួរតែទទួលបានការបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ពួកគេ និងអាចផ្តល់ជូនសេវាកម្មដែលមានមេត្រីភាព និងជាក់លាក់សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា។ នេះរួមបញ្ចូលទាំងការបណ្តុះបណ្តាលគ្រូ អំពីរបៀបដើម្បីគាំទ្រសិស្សនិស្សិតដែលមិនមែនជាអ្នកស្រឡាញ់ភេទផ្ទុយគ្នា និងផ្តល់ការណែនាំដល់និយោជក វិស័យឯកជន អំពីរបៀបគោរព ការពារ និងលើកកម្ពស់សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកន្លែងធ្វើការ។

៣. អង្គការក្នុងស្រុក និងអង្គការអន្តរជាតិគួរតែលើកទឹកចិត្ត និងផ្តល់ឱកាសដល់អ្នកស្រឡាញ់ភេទដូចគ្នាដើម្បីបង្កើនជំនាញវិជ្ជាជីវៈដើម្បីចាប់ផ្តើមមុខរបរ និងស្វែងរកការងារធ្វើ។

៤. ស្ថាប័នហិរញ្ញវត្ថុ និងធនាគារខ្នាតតូច គួរផ្តល់ប្រាក់កម្ចីដោយមានលក្ខខណ្ឌអាចបត់បែនបានចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ដែលមានបំណងចាប់ផ្តើមអាជីវកម្មខ្នាតតូច។

## ៣. សេចក្តីផ្តើម

មូលនិធិអេបខម (Apcom) បង្កើតឡើងក្នុងឆ្នាំ២០០៧ នៅឯទីក្រុងបាងកក ជាអង្គការមិនស្វែងរកប្រាក់ចំណេញ ដែលជាតំណាង និងធ្វើការងារជាមួយបណ្តាញបុគ្គល និងអង្គការសហគមន៍នៅទូទាំងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

អេបខម (Apcom) ធ្វើការលើកកម្ពស់ផ្នែកសុខភាព និងសិទ្ធិបុរសស្រឡាញ់ភេទដូចគ្នា បុរសរួមភេទជាមួយបុរស រួមទាំងប្រជាជន ក៏ដូចជាសហគមន៍ចម្រុះនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងលក្ខណៈភេទ (SOGIESC) នៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ អេបខម ផ្តោតចម្បងលើមេរោគអេដស៍ ព្រោះវាគឺជាបញ្ហាសុខភាពដ៏សំខាន់សម្រាប់បុរសស្រឡាញ់ភេទដូចគ្នា និងបុរសរួមភេទជាមួយបុរសផ្សេងទៀតនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ អេបខម មានគោលបំណងចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាសុខភាពដែលពាក់ព័ន្ធផ្សេងទៀតសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដូចជាសុខភាពផ្លូវភេទ សុខភាពផ្លូវចិត្ត និងការប្រើប្រាស់គ្រឿងញៀន។ អេបខម ក៏ផ្តោតលើការលើកកម្ពស់សិទ្ធិមនុស្ស និងច្បាប់ដែលពាក់ព័ន្ធនៅទូទាំងថ្នាក់តំបន់ ដូចជាការរើសអើង ការមាក់ងាយ បទឧក្រិដ្ឋ និងការផាត់ចេញ ដែលមានផលប៉ះពាល់លើសុខភាពរបស់សហគមន៍ដែលយើងធ្វើការជាមួយ។

មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) មានទស្សនៈវិស័យចង់បង្កើតពិភពលោកមួយដែលអ្នកស្រឡាញ់ភេទដូចគ្នា (LGBTI) រស់នៅដោយគ្មានការរើសអើង ការធ្វើទុក្ខបុកម្នេញ និងមានឱកាសស្មើភាពគ្នាក្នុងជីវិត រួមមានការទទួលបានការងារ ការបណ្តុះបណ្តាល ការអប់រំ សេវាកម្មហិរញ្ញវត្ថុ ការថែរក្សាសុខភាព លំនៅដ្ឋាន ទីកន្លែងជំនឿ និងសេវាសាធារណៈ។

មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) មានបេសកកម្មបង្កើតឧបករណ៍ កម្មវិធី ផ្តល់អនុសាសន៍លើគោលនយោបាយ ដើម្បីអ្នកស្រឡាញ់ភេទដូចគ្នាអាចរួមផុតពីភាពក្រីក្រនៅគ្រប់ទីកន្លែង។ មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) ជឿជាក់ថាអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននៅទូទាំងពិភពលោកកាន់តែងាយរងគ្រោះដោយភាពក្រីក្រ ដោយសារតែនិន្នាការភេទ និង/ឬអត្តសញ្ញាណយេនឌ័រ ឬអន្តរភេទ។ ចាប់តាំងពីឆ្នាំ២០១២ មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) ចាប់ផ្តើមអនុវត្តកម្មវិធីការកាត់បន្ថយភាពក្រីក្រចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។

### ហេតុផលនៃរបាយការណ៍ និងជំហានបន្ទាប់

រឿងរ៉ាវនៃការមាក់ងាយ និងការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នកស្រឡាញ់ភេទដូចគ្នាមាននៅទូទាំងពិភពលោក។ រឿងរ៉ាវទាំងនេះពោរពេញទៅដោយបទពិសោធន៍នៃឧបសគ្គ និងបញ្ហានានាក្នុងការទទួលបានមូលដ្ឋានផ្នែកសេដ្ឋកិច្ចសង្គម និងសិទ្ធិវប្បធម៌ រួមបញ្ចូលទាំងសិទ្ធិការងារ ការអប់រំ ការថែទាំសុខភាព និងការចូលរួមក្នុងវិស័យសេដ្ឋកិច្ច និងធនធានហិរញ្ញវត្ថុ។

ធនាគារពិភពលោកបង្ហាញថា *ទោះបីជាមានភាពជឿនលឿនផ្នែកច្បាប់ និងផ្នែកសង្គមក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះក៏ដោយ អ្នកស្រឡាញ់ភេទដូចគ្នា (LGBTI) នៅតែបន្តប្រឈមមុខនឹងការរើសអើង និងអំពើហឹង្សានៅក្នុងបណ្តាប្រទេសជាច្រើន។ ការរើសអើង និងអំពើហឹង្សាទាំងនេះធ្វើអោយមានការផាត់ចេញមិនរាប់បញ្ចូល ហើយការមិនរាប់បញ្ចូលនេះមានផលប៉ះពាល់អវិជ្ជមានដល់ជីវិតអ្នកស្រឡាញ់ភេទដូចគ្នា ក៏ដូចជាក្នុងសហគមន៍ និងផ្នែកសេដ្ឋកិច្ចដែលពួកគាត់រស់នៅ*[9]។

ធនាគារពិភពលោកក៏បានបញ្ជាក់ផងដែរថា *មានការកើនឡើងនូវភស្តុតាងបង្ហាញថាអ្នកស្រឡាញ់ភេទដូចគ្នាទទួលបានការអប់រំទាបដោយសារការរើសអើង ការសម្លុតមាក់ងាយ និងអំពើហិង្សា។ មានអត្រាគ្មានការងារធ្វើខ្ពស់ និងកង្វះលទ្ធភាពទទួលបានលំនៅដ្ឋាន ក៏ដូចជាសេវាសុខភាព និងសេវាកម្មហិរញ្ញវត្ថុគ្រប់គ្រាន់*[10]

[9] The World Bank: Sexual Orientation and Gender Identity. At: https://www.worldbank.org/en/topic/sexual-orientation-and-gender-identity
[10] Ibid.

របាយការណ៍នៅកម្ពុជា មានគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅអំពីរបៀបដែលសិទ្ធិមនុស្សនៃអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា ត្រូវបានរៀបចំអោយមានឡើង និងបញ្ហាប្រឈម រួមទាំងឱកាសសំខាន់ៗនាពេលបច្ចុប្បន្នសម្រាប់ការរួមបញ្ចូលក្នុងសង្គម ផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់អ្នកស្រឡាញ់ភេទដូចគ្នា។

មានភ័ស្តុតាងជាច្រើនចាំបាច់ត្រូវប្រមូលក្នុងការដាក់បញ្ចូលក្នុងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃអ្នកស្រឡាញ់ភេទដូចគ្នា។ បន្ថែមលើការយល់ដឹងអំពីរបាយការណ៍នេះ និងរបាយការណ៍ចំនួន៣ ផ្សេងទៀតដែលនឹងបង្កើតជាមូលដ្ឋានសម្រាប់ការរៀនសូត្រ និងយុទ្ធសាស្ត្រថ្មីៗ លទ្ធផលការរកឃើញនេះក៏នឹងផ្តល់ជាដំណឹងអំពីសមាសធាតុគម្រោងបន្ថែម រួមមានការស្វែងរកការគាំទ្រពីខាងវិស័យឯកជន រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ។ ដូចគ្នានេះដែរគំនិតផ្តួចផ្តើមនេះនឹងមានគោលដៅធ្វើឱ្យប្រសើរឡើងនាពេលអនាគត។

ការស្រាវជ្រាវ និងសំឡេងរបស់អ្នកស្រឡាញ់ភេទដូចគ្នាដែលបានចូលរួមក្នុងការសិក្សានេះនឹងចូលរួមចំណែក និងផ្តល់ជាដំណឹងដល់ការបង្កើតសកម្មភាពនាពេលអនាគតក្នុងការចូលរួមជាមួយស្ថាប័នហិរញ្ញវត្ថុ និងវិស័យឯកជនទាំងក្នុងប្រទេស និងនៅទូទាំងប្រទេសទាំង៤ ក្នុងគោលបំណងឆ្ពោះទៅរកការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងលក្ខខណ្ឌនៃគោលនយោបាយការអនុវត្ត និងកម្មវិធីនានា។

## វិធីសាស្ត្រនៃការស្រាវជ្រាវ និងការពិភាក្សាក្រុម

ការស្រាវជ្រាវមានទាំងការពិនិត្យលើអត្ថបទឯកសារ និងការពិភាក្សាក្រុមដែលធ្វើឡើងក្នុងរវាងខែកក្កដា និងខែតុលា ឆ្នាំ២០១៩។ ផ្នែកនៃការស្រាវជ្រាវនេះរួមមានការត្រួតពិនិត្យទិន្នន័យជាក់លាក់របស់ប្រទេស និងការស្រាវជ្រាវផ្សេងៗកន្លងមកដែលពាក់ព័ន្ធនឹងការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា។

ការពិភាក្សាក្រុមចំនួនបី ត្រូវបានធ្វើឡើងដោយដើរតាមបញ្ជីសំណួរដែលបានរៀបចំទុកជាមុនពីអេបខម (Apcom) សហការណ៍ជាមួយមូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) ក្នុងគោលបំណងដើម្បីចាប់យកភាពពិតជាក់ស្តែងនៃការរស់នៅរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ ក្រុមពិភាក្សាទី១ រួមមានបុរសស្រឡាញ់ភេទដូចគ្នា និងបុរសស្រឡាញ់ទាំងពីរភេទ ក្រុមពិភាក្សាទី២ មានស្ត្រីប្តូរយេនឌ័រទៅជាបុរស និងស្ត្រីស្រឡាញ់ភេទដូចគ្នា និងក្រុមពិភាក្សាទី៣ មានបុរសប្តូរយេនឌ័រទៅជាស្ត្រី។ សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាសរុបចំនួន ៣២ នាក់បានចូលរួមៈ ដែលមានស្ត្រីស្រឡាញ់ភេទដូចគ្នា ៣នាក់ បុរសស្រឡាញ់ភេទដូចគ្នា ៧នាក់ បុរសស្រឡាញ់ទាំងពីរភេទ ៥នាក់ ស្ត្រីប្តូរយេនឌ័រទៅជាបុរស៤នាក់និងបុរសប្តូរយេនឌ័រទៅជាស្ត្រីចំនួន ១៣នាក់។

អ្នកចូលរួមក្នុងក្រុមពិភាក្សាភាគច្រើនមានអាយុពី ២២-៣០ឆ្នាំ (ចំនួន ១០នាក់) និង ៣១-៤៥ឆ្នាំ (ចំនួន ១៦នាក់)។ អ្នកចូលរួមដែលក្មេងជាងគេជាស្ត្រីស្រឡាញ់ភេទដូចគ្នាម្នាក់មានអាយុ ២១ឆ្នាំ ហើយអ្នកដែលចាស់ជាងគេគឺជាស្ត្រីប្តូរយេនឌ័រទៅជាបុរសម្នាក់អាយុ ៧៤ឆ្នាំ។ បើនិយាយពីមុខរបររបស់ពួកគេវិញ អ្នកចូលរួមភាគច្រើនធ្វើការនៅសំអាងការ (១៦នាក់) ឬក៏ជាជនសកម្មដែរ (១២នាក់)។ ការងារវិជ្ជាជីវៈផ្សេងទៀតដូចជា ជំនួយការផ្នែកលក់ (៣នាក់) សិល្បករ (២នាក់) កសិករ (២នាក់) សិស្សនិស្សិត (២នាក់) បុគ្គលិកសណ្ឋាគារ មន្ត្រីរាជការ កម្មកររោងចក្រ ចុងភៅ ជាងកាត់ដេរ និងអ្នកថែទាំ។

ការពិភាក្សាក្រុមធ្វើឡើងនៅកន្លែងសុវត្ថិភាពដែលមានការយល់ព្រមជាមុនពីអ្នកចូលរួមទាំងអស់។ អ្នកចូលរួមខ្លះក៏បានការយល់ព្រមឱ្យថតរូបពួកគេ ដើម្បីប្រើប្រាស់ជាសម្ភារៈនាពេលអនាគតសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ ភាពអនាមិកត្រូវបានគោរពសម្រាប់អ្នកដែលមិនចង់បញ្ចេញឈ្មោះ។

អ្នកចូលរួមត្រូវបានសួរ ដើម្បីផ្តល់មតិយោបល់ស្ថាបនាបន្ទាប់ពីពិភាក្សាក្រុមរួច។ អ្នកចូលរួមភាគច្រើនរីករាយក្នុងការចែករំលែកបញ្ហាប្រឈម និងការរស់នៅជាក់ស្តែងរបស់ពួកគេ ហើយរីករាយក្នុងការរៀនសូត្រពីគ្នាទៅវិញទៅមក ទោះបីជាប្រធានបទខ្លះមានលក្ខណៈរសើបខ្លាំងក្នុងការពិភាក្សាក៏ដោយ។ពួកគេក៏កោតសរសើរផងដែរចំពោះឱកាសដើម្បីបញ្ចេញសំឡេងរបស់ពួកគេនៅកន្លែងដែលមានសុវត្ថិភាព និងដើម្បីផ្តល់យោបល់សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវជីវិតរបស់អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា។

## វិសាលភាព និងដែនកំណត់នៃរបាយការណ៍នេះ

ខណៈពេលដែលយើងទទួលស្គាល់វិសាលភាពនៃការស្រាវជ្រាវនៅមានកំណត់ និងចង់បញ្ជាក់ឱ្យច្បាស់ថាការស្រាវជ្រាវនេះមិនបានអះអាងទូលំទូលាយ ហើយក៏មិនបង្ហាញរូបភាពពេញលេញនៃស្ថានភាពទាំងស្រុងរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាដែរ។យើងជឿជាក់ថាវាមានភ័ស្តុតាងសំខាន់ៗនៃឧសគ្គបច្ចុប្បន្ន និងឱកាសសម្រាប់លើកស្ទួយការដាក់បញ្ចូលក្នុងវិស័យសេដ្ឋកិច្ចរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ នៅពេលបញ្ចូលលទ្ធផលការស្រាវជ្រាវពីមុន រួមទាំងរបាយការណ៍ស្រាវជ្រាវឆ្នាំ២០១៨ "*ការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាក្នុងវិស័យសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍៖ ការស្រាវជ្រាវនៅប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ឡាវ និង ហ្វីលីពីន*"[11] ក៏ដូចជារបាយការណ៍ប្រទេស៣ បន្ថែមទៀតលើប្រទេសឥណ្ឌូនេស៊ី ឡាវ និងហ្វីលីពីន លំនាំមួយលេចចេញមកដែលគួរតែត្រូវបានរកឃើញយ៉ាងល្អិតល្អន់ជាងមុន ដោយធ្វើការបង្កើតទិន្នន័យ រួមទាំងការស្រាវជ្រាវបែបគុណភាព និងបែបបរិមាណការស្ទង់មតិ ការបង្កើតទិន្នន័យ និងការវិភាគឱ្យកាន់តែស៊ីជម្រៅ។

ចំពោះរបាយការណ៍នេះ ក៏ពាក់ព័ន្ធក្នុងការគូសបញ្ជាក់អំពីការមានកំណត់នៃការស្រាវជ្រាវជាចម្បងពីរផងដែរ៖ ទី១ យើងទទួលស្គាល់ថាអ្នកចូលរួមមានចំនួនតិចដែលភាគច្រើនមកពីទីក្រុង និងទីប្រជុំជន នោះហើយយើងមិនអាចអះអាងថាការរស់នៅជាក់ស្តែងរបស់ពួកគេ គឺតំណាងអោយអ្នកស្រលាញ់ភេទទាំងអស់នៅកម្ពុជានោះទេ។ យើងចង់ចង្អុលបង្ហាញថាមួយនៅក្នុងគោលបំណងនៃការស្រាវជ្រាវនេះ គឺការអំពាវនាវដើម្បីប្រមូលទិន្នន័យបន្ថែមអំពីបទពិសោធន៍នៃការផាត់ចេញមិនដាក់បញ្ចូលអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា ជាជាងបង្កើតការវិភាគស្ថិតិទូលាយមួយលើប្រធានបទ។ ទី២ មិនមានការចូលរួមពីមនុស្សដែលកំណត់អត្តសញ្ញាណជាអន្តរភេទ ឬបុគ្គលដែលមិនកំណត់ខ្លួនឯង នៅក្នុងកិច្ចពិភាក្សាក្រុមទេ ដោយសារតែក្រុមអ្នកស្រាវជ្រាវមិនអាចស្វែងរកពួកគាត់បាន។ បុគ្គលអន្តរភេទ ឬបុគ្គលដែលមិនកំណត់ខ្លួនឯង គឺនៅតែមិនទាន់មើលឃើញច្បាស់នៅឡើយក្នុងប្រទេសកម្ពុជា ហើយម្យ៉ាងវិញទៀតអង្គការដៃគូមិនទាន់ធ្វើការងារផ្ទាល់ជាមួយក្រុមនេះនៅឡើយទេ។

### និយមន័យ និងពាក្យ ការដាក់បញ្ចូលក្នុងវិស័យសេដ្ឋកិច្ច

យើងប្រើនិយមន័យនេះតាមធនាគារអឺរ៉ុបសម្រាប់ការស្តាបនាឡើងវិញនិងការអភិវឌ្ឍ៖ "ដាក់បញ្ចូលក្នុងវិស័យសេដ្ឋកិច្ច៖ ជាការបើកឱកាសផ្នែកសេដ្ឋកិច្ចដល់ក្រុមសង្គមដែលមិនមានការទទួលខុសត្រូវគឺជាកត្តាដ៏សំខាន់ចំពោះ [...] សេដ្ឋកិច្ចទីផ្សារប្រកដោយចីរភាព។ សេដ្ឋកិច្ចទីផ្សារដែលមានការដាក់បញ្ចូល ធានាអោយបានថា បុគ្គលគ្រប់រូបដោយមិនគិតពីយេនឌ័រ ទីកន្លែងកំណើត ប្រវត្តិគ្រួសារ អាយុ ឬស្ថានភាពដទៃៗទៀត ដែលពួកគេមិនត្រូវបានគ្រប់គ្រង មានសិទ្ធិពេញលេញ និងយុត្តិធម៌ក្នុងទីផ្សារការងារ ហិរញ្ញវត្ថុ និងសហគ្រិនភាព ហើយជាទូទៅនៃឱកាសសេដ្ឋកិច្ច"។[12]

### ការផាត់ចេញ ឬការមិនដាក់បញ្ចូល

ក្នុងការកំណត់ពាក្យការផាត់ចេញ ឬការមិនដាក់បញ្ចូល យើងយកការបំផុសគំនិតចេញពីនិយមន័យដែលត្រូវបានប្រើដោយសាស្ត្រាចារ្យ Prof. Lee Badgett មានន័យថា "រចនាសម្ព័ន្ធនៃការមាក់ងាយនៅក្នុងការរៀបចំស្ថាប័ន ការកាត់បន្ថយការទទួលបានសេវា និងការចូលរួមស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងស្ថាប័នសង្គមជាច្រើនផ្នែកដូចជាសាលារៀនកន្លែងធ្វើការ ការថែទាំសុខភាព ដំណើរការនយោបាយ ប្រព័ន្ធហិរញ្ញវត្ថុ ប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌ ក្រុមគ្រួសារ កម្មវិធីរបស់រដ្ឋាភិបាល និងក្នុងច្បាប់ រួមទាំងគោលនយោបាយផ្សេងៗ"។[13]

---

11 https://nf3y0lqssvfx.cdn.shift8web.com/wp-content/uploads/2020/10/Report_Economic-Inclusive_v5.pdf

12 European Bank for Reconstruction and Development. At: https://www.ebrd.com/what-we-do/projects-and-sectors/economic-inclusion.html

13 Badgett, Lee, et al. (2014). The Relationship Between LGBT Inclusion and Economic Development: An Analysis of Emerging Economies. The Williams Institute, Los Angeles, USA. November 2014. At https://williamsinstitute.law.ucla.edu/wp-content/uploads/lgbt-inclusion-and-development-november-2014.pdfhttps://williamsinstitute.law.ucla.edu/publications/lgbt-inclusion-economic-dev/

**ការដាក់បញ្ចូលក្នុងផ្នែកហិរញ្ញវត្ថុ**

យើងប្រើប្រាស់និយមន័យរបស់ ធនាគារពិភពលោក "ការដាក់បញ្ចូលក្នុងផ្នែកហិរញ្ញវត្ថុ មានន័យថាគ្រប់បុគ្គល និងអាជីវកម្មទាំងអស់មានលទ្ធភាពទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលមានប្រយោជន៍ និងតម្លៃសមរម្យដែលឆ្លើយតបនឹងតម្រូវការរបស់ពួកគេដូចជាៈ ប្រតិបត្តិការ ការទូទាត់ប្រាក់ ការសន្សំ ឥណទាន និងធានារ៉ាប់រងផ្តល់ជូនដោយការទទួលខុសត្រូវ និងប្រកបដោយ និរន្តរភាព។"[14]

អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI)យើងប្រើប្រាស់អក្សរកាត់ LGBTQI ជាពាក្យថា អ្នកស្រឡាញ់ភេទដូចគ្នា សំដៅទៅដល់ស្ត្រីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អ្នកមិនកំណត់ខ្លួនឯងជាអ្នកណា និងបុគ្គលអន្តរភេទ រួមទាំងសហគមន៍ផ្សេងៗទៀត។ អេបខម(Apcom) ទទួលស្គាល់ថាមានភាពចម្រុះផ្សេងៗគ្នារវាងវប្បធម៌ និងបរិបទនៃប្រទេសក្នុងការប្រើប្រាស់ពាក្យទាំងនេះ និងពាក្យដែលពាក់ព័ន្ធ ហើយដែលភាសាខ្លះមិនមានពាក្យជាក់លាក់ដើម្បីពិពណ៌នាអំពីនិន្នាការភេទ និង/ឬអត្តសញ្ញាណ និងការបញ្ចេញយេនឌ័រ។

យើងប្រើប្រាស់វាក្យស័ព្ទដោយផ្អែលលើគោលការណ៍យកគីយ៉ាកាតា +១០ (Yogayakarta Principles +10) ហើយប្រើអក្សរកាត់ SOGIESC (សូជីអេសស៊ី) ដើម្បីពិពណ៌នាជារួមអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រនិងលក្ខណៈភេទ។[15]

## សូជីអេសស៊ី (SOGIESC)

**និន្នាការ** ភេទសំដៅលើមនោសញ្ចេតនាជ្រាលជ្រៅ អារម្មណ៍នៃសេចក្តីស្រឡាញ់ និងការទាក់ទាញផ្លូវភេទ ចំណង់ស្និទស្នាល និងទំនាក់ទំនងផ្លូវភេទរបស់បុគ្គលម្នាក់ ទៅកាន់បុគ្គលផ្សេងទៀតដែលមានយេនឌ័រខុសគ្នា ឬដូចគ្នា ឬច្រើនជាងមួយយេនឌ័រ។

**អត្តសញ្ញាណយេនឌ័រ** សំដៅលើអារម្មណ៍ខាងក្នុងផ្ទាល់ខ្លួន និងបទពិសោធន៍របស់បុគ្គលម្នាក់ទៅលើយេនឌ័ររបស់ខ្លួន ដែលអាច ឬមិនអាចស៊ីសង្វាក់ទៅនឹងភេទពីកំណើតរបស់ខ្លួន រាប់បញ្ចូលទាំងអារម្មណ៍ផ្ទាល់ខ្លួននៃរាងកាយ (ដែលអាចពាក់ព័ន្ធនឹងការជ្រើសរើសរូបរាង ឬមុខងាររាងកាយដោយប្រើវេជ្ជសាស្ត្រ ការវះកាត់ ឬមធ្យោបាយផ្សេងទៀត) និងការបង្ហាញនៃយេនឌ័រផ្សេងទៀត រួមមានការស្លៀកពាក់ ការនិយាយ និងលក្ខណៈផ្សេងៗ។

**ការបង្ហាញយេនឌ័រ** សំដៅលើការបង្ហាញនូវយេនឌ័ររបស់បុគ្គលម្នាក់ៗតាមរយៈរូបរាងកាយខាងក្រៅរបស់ខ្លួន រួមមានសម្លៀកបំពាក់ ស្ទីលម៉ូដសក់ គ្រឿងប្រើប្រាស់ផ្សេងៗ ការតុបតែងខ្លួន និងចរិតលក្ខណៈផ្សេងៗ ការនិយាយ ឥរិយាបទអាកប្បកិរិយា ការដាក់ឈ្មោះ និងឯកសារយោងផ្ទាល់ខ្លួនដែលអាច ឬមិនស្របតាមអត្តសញ្ញាណយេនឌ័ររបស់មនុស្សម្នាក់។

**លក្ខណៈភេទ** សំដៅទៅលើលក្ខណៈពិសេសនៃរាងកាយរបស់មនុស្សម្នាក់ៗទាក់ទងនឹងភេទ រួមមានសរីរៈប្រដាប់បន្តពូជ រួមទាំងកាយវិភាគសាស្ត្រផ្លូវភេទ និងបន្តពូជដទៃទៀត ក្រូម៉ូសូម អ័រម៉ូន និងលក្ខណៈរូបវន្តបន្ទាប់បន្សំកើតឡើងពីភាពពេញវ័យ។

**ការដាក់បញ្ចូល( បរិយាបន )** នៅក្នុងសង្គមដំណើរការនៃកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីធានាបាននូវឱកាសស្មើភាពគ្នា សម្រាប់មនុស្សគ្រប់រូបដោយមិនគិតពីប្រវត្តិរបស់ពួកគេ អោយអាចទទួលបានសក្តានុពលពេញលេញនៅក្នុងជីវិត។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមមាន គោលនយោបាយ ការអនុវត្ត និងសកម្មភាពដែលលើកកម្ពស់ការទទួលបានសេវាសាធារណៈស្មើភាពគ្នា ក៏ដូចជាធ្វើអោយប្រជាជន និងពលរដ្ឋចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដែលមានផលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។

---

[14] The World Bank. Financial Inclusion. At: http://www.worldbank.org/en/topic/financialinclusion/overview

[15] Yogyakarta Principles Plus 10 (YP+10) (2017) is an authoritative statement of the human rights of persons of diverse sexual orientations and gender identities. At: https://yogyakartaprinciples.org/

## ៤. បរិបទសិទ្ធិមនុស្សបច្ចុប្បន្ន និងការជះឥទ្ធិពលលើអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា

ប្រទេសកម្ពុជាជាប្រទេសក្រីក្រមួយក្នុងចំណោមប្រទេសក្រីក្របំផុត ដែលចាប់ផ្តើមគ្រឹះប្រជាធិបតេយ្យនាពេលថ្មីៗនេះ។ បន្ទាប់ពីសង្គ្រាមស៊ីវិលជាច្រើនទសវត្សជម្លោះប្រដាប់អាវុធ របបផ្តាច់ការ ការឈ្លានពានពីបរទេស និងភាពចលាចល ការបោះឆ្នោតជាតិលើកដំបូងត្រូវបានធ្វើឡើងនៅឆ្នាំ១៩៩៣ ដោយសារប្រតិបត្តិការរក្សាសន្តិភាពដោយអង្គការសហប្រជាជាតិ។[16] ការបោះឆ្នោឃុំសង្កាត់លើកដំបូង[17] ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០០ និងបានរៀបចំការបោះឆ្នោតព្រឹទ្ធសភាលើកដំបូងឆ្នាំ២០០៦។[18] ចាប់តាំងពីពេលនោះមកសង្គមស៊ីវិល និអង្គការក្រៅរដ្ឋាភិបាលបានបង្កើនការចូលរួមបន្តិចម្តងៗនៅក្នុងប្រព័ន្ធនយោបាយ និងការជជែកដេញដោលអំពីបញ្ហាសិទ្ធិមនុស្សរបស់ប្រទេស ដែលនៅតែត្រូវបានសម្គាល់ដោយធាតុផ្សំក្រោយជម្លោះ និងធាតុផ្សំនៃការអភិរក្សនិយម។

ទោះបីត្រូវបានគេស្គាល់ជាប្រវត្តិសាស្ត្រថាជាប្រទេសអភិរក្សទាក់ទងនឹងសិទ្ធិមនុស្សក៏ដោយ ក៏ស្ថានភាពប្រជាធិបតេយ្យនៅកម្ពុជាមានការផ្លាស់ប្តូរជាបណ្តើរៗក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ ហើយការជជែកវែកញែកជុំវិញសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា ទទួលបានការយកចិត្តទុកដាក់កាន់តែច្រើនឡើងពីរដ្ឋាភិបាល និងវិស័យទទៃផ្សេងទៀតនៅក្នុងសង្គម។ម្យ៉ាងវិញទៀតក៏មានសញ្ញាវិជ្ជមានពីរដ្ឋាភិបាលលើការទទួយកលទ្ធផលនៃការត្រួតពិនិត្យជាសាកលតាមកាលកំណត់របស់អង្គការសហប្រជាជាតិ(UPR) ជុំទី៣ នាពេលថ្មីៗនេះ ដែលពាក់ព័ន្ធនឹងការពិនិត្យឡើងវិញនូវកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋសមាជិកភាពនៃអង្គការសហប្រជាជាតិទាំងអស់ រួមទាំងស្ថានភាពសិទ្ធិរបស់ក្រុមមនុស្សភាគតិច និងអ្នកស្រឡាញ់ភេទដូចគ្នា។[19] រដ្ឋាភិបាលទទួលយកអនុសាសទាំង ៩ ចំណុចទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណឬការបង្ហាញយេនឌ័រ។[20] ទោះយ៉ាងណាក៏ដោយ ស្ថិតនៅក្នុងដំណាក់កាលថាតើអនុសាសន៍ទាំងនេះនឹងត្រូវបានយកមកអនុវត្តដែរឬទេ។

ផ្ទុយពីប្រទេសជាច្រើន ការស្រឡាញ់ភេទដូចគ្នាមិនដែលខុសច្បាប់នៅក្នុងប្រទេសកម្ពុជាទេ។ ទោះបីយ៉ាងណា អាពាហ៍ពិពាហ៍ភេទដូចគ្នាត្រូវបានហាមឃាត់ដោយច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ដែលបានចែងថា "អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិករវាងបុរសម្នាក់ និងស្ត្រីម្នាក់" (មាត្រា ៣) ហើយថាមិនអាចរៀបអាពាហ៍ពិពាហ៍បានរវាង "បុគ្គលមានភេទដូចគ្នា" (មាត្រា ៦) ។[21] បទប្បញ្ញត្តិបែបនេះត្រូវបាននិរាកដោយក្រមរដ្ឋប្បវេណីឆ្នាំ ២០០៨ និងច្បាប់ឆ្នាំ ២០១១ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ទោះបីជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរនេះមិនបានផ្សព្វផ្សាយអោយបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅ រួមទាំងមន្ត្រីរដ្ឋាភិបាលក្នុងថ្នាក់មូលដ្ឋានដែលចេញលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ទេ។[22]

ទោះបីជាច្បាប់រដ្ឋធម្មនុញ្ញពន្យល់ថាអាពាហ៍ពិពាហ៍ គឺ "តាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ"[23] "ដោក៏មានសេចក្តីរាយការណ៍អំពីគូស្វាមីភរិយាភេទដូចគ្នាដែលអាចទទួលបានសំបុត្រអាពាហ៍ពិពាហ៍ដោយចុះឈ្មោះ

[16] United Nations Transitional Authority in Cambodia (UNTAC). At: https://peacekeeping.un.org/sites/default/files/past/untac.htm

[17] Communes are the third-level administrative divisions in Cambodia (after District and Province). Communes consist of between 3 and 30 villages.

[18] The World Bank (2005). Country Assessment Strategy (CAS) for the Kingdom of Cambodia. At: http://documents1.worldbank.org/curated/en/117651468212979440/pdf/32118.pdf

[19] For more information on the outcome of the UPR, see letter dated 19 August 2019 from the UN High Commissioner for Human Rights, Michelle Bachelet, to the Cambodian Minister of Foreign Affairs and International Cooperation, H.E. Mr. Prak Sohkhonn. At: https://lib.ohchr.org/HRBodies/UPR/Documents/Session32/KH/HC_letter_Cambodia_ENG.pdf

[20] United Nations Human Rights Council: Universal Periodic Review (UPR) (Third Cycle) 2019: Cambodia; Matrix of recommendations (English). At: https://www.ohchr.org/EN/HRBodies/UPR/Pages/KHindex.aspx

[21] Cambodia: Law of 1989 on the Marriage and Family. At: https://www.refworld.org/docid/3ae6b55c0.html.

[22] UNDP, USAID. (2014). Being LGBTI in Asia: Cambodia Country Report. Bangkok. At: https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf

[23] Constitution of the Kingdom of Cambodia. At: https://www.wipo.int/edocs/lexdocs/laws/en/kh/kh009en.pdf

ជា" ប្តី" និង" ប្រពន្ធ"។[24] តាមពិតទៅយុទ្ធសាស្រ្តនេះត្រូវបានគាំទ្រដោយមន្ត្រីក្រសួងមហាផ្ទៃ ដែលបានអះអាងថា ប្រទេសកម្ពុជាមិនបានហាមឃាត់ការរៀបការភេទដូចគ្នាទេ និងបានស្នើថា "នៅពេលមានអាពាហ៍ពិពាហ៍រវាងស្ត្រី និងស្ត្រី អ្នកអាចចុះឈ្មោះម្នាក់ជាបុរស និងម្នាក់ទៀតជាស្ត្រី"[25] ដូច្នេះដើម្បីបន្ថែមទៅតាមលំដាប់លំដោយនៃស្តង់ដាស្រឡាញ់ភេទផ្ទុយគ្នា ដែលគ្របដណ្តប់នៅក្នុងសង្គមកម្ពុជា។

ការទទួលស្គាល់ផ្លូវច្បាប់នៃទំនាក់ទំនងភេទដូចគ្នានេះ ផ្ទុយពីការដែលប្រទេសកម្ពុជាបោះបង់ចោលទាក់ទងទៅនឹងសិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នា។ ក្រសួងរដ្ឋាភិបាលមិនទាន់មានកម្មវិធី ឬគោលនយោបាយផ្តោតលើអ្នកស្រឡាញ់ភេទដូចគ្នានៅឡើយទេ។ មិនមានច្បាប់ប្រឆាំងនឹងការរើសអើ ឬច្បាប់ផ្សេងទៀតដើម្បីការពារប្រជាពលរដ្ឋដែលប្រឆាំងនឹងការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រ ឬការទទួលស្គាល់សិទ្ធិសំខាន់ៗសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាកម្ពុជា ដូចជាអាពាហ៍ពិពាហ៍ មរតក ប្រាក់សោធននិវត្តន៍ ការសុំកូនចិញ្ចឹមរួមគ្នា ឬការចាត់តាំងយេនឌ័រឡើងវិញជាដើម។

បើគ្មានការការពារផ្នែកច្បាប់ទេ អ្នកស្រឡាញ់ដូចគ្នាកម្ពុជានៅតែទទួលរងការមាក់ងាយ ការរើសអើង ការរំលោភបំពានពីប៉ូលីស អំពើហិង្សាក្នុងគ្រួសារ និងផ្លូវភេទ និងការមិនទទួលស្គាល់ពីក្រុមគ្រួសាររបស់ពួកគេ។ យោងតាមយូអិនឌីភី (UNDP) និង USAID ឆ្នាំ២០១៤[26] អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកបានរាយការណ៍ថាមានការចាប់ខ្លួន និងការបៀតបៀនអ្នកស្រឡាញ់ភេទដូចគ្នាជាចៃដន្យដោយប៉ូលីសដែលធម្មតាគឺប្រើច្បាប់ និងគោលនយោបាយប្រឆាំងបទឧក្រិដ្ឋផ្សេងៗទូទៅ ដើម្បីធ្វើទុក្ខបុកម្នេញអ្នកស្រលាញ់ភេទដូចគ្នា និងភ្ជាប់ពួកគេជាមួយនឹងឧក្រិដ្ឋកម្ម ការប្រព្រឹត្តមិនត្រឹមត្រូវ និងការប្រើប្រាស់គ្រឿងញៀន។ ក៏មានសេចក្តីរាយការណ៍ផងដែរអំពីដៃគូស្រឡាញ់ភេទដូចគ្នាដែលបានរងគ្រោះដោយការចាប់បំបែកពីអាជ្ញាធរមូលដ្ឋាន ក្នុងការឆ្លើយតបចំពោះការដាក់សំពាធពីសមាជិកក្រុមគ្រួសាររបស់ពួកគេផ្ទាល់។

ការរើសអើង និងការប្រកាន់ចំពោះអ្នកស្រឡាញ់ភេទដូចគ្នាកម្ពុជា ហាក់ដូចជាត្រូវបានជំរុញដោយការសង្កត់ធ្ងន់របស់សង្គមទៅលើគុណតម្លៃគ្រួសារតាមបែបប្រពៃណី និងមិនមែនដោយសារបញ្ហាជំនឿសាសនាដូចនឹងករណីនៅក្នុងប្រទេសដទៃទៀតដែរ។ របាយការណ៍ឆ្នាំ ២០១០ ពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានអះអាងថា "ដោយសារវប្បធម៌នេះភាគច្រើនជាព្រះពុទ្ធសាសនា ការស្រឡាញ់ភេទដូចគ្នា ខណៈដែលត្រូវបានគេមើលឃើញថាគ្រាន់ជារឿងចម្លែកមួយ មិនមែនទាក់ទាញប្រភេទនៃប្រតិកម្មប្រឆាំងតបត ដូចដែលអាចឃើញនៅក្នុងវប្បធម៌របស់សាសនាគ្រីស្ទ ឬមូស្លីមនោះទេ។"[27]

ដូច្នេះឧក្រិដ្ឋកម្មនៃការស្អប់ប្រហែលជាមិនបានកើតឡើងទូទៅនៅក្នុងប្រទេសក៏ពិតមែន ប៉ុន្តែមានការដាក់សំពាធទៅរកចំណងអាពាហ៍ពិពាហ៍ភេទផ្ទុយគ្នា និងការបង្កើតកូននៅតែត្រូវបានគេចាត់ទុកថាជាគោលដៅជីវិតចុងក្រោយ ទាំងចេញពីទស្សនៈខាងសីលធម៌ និងសេដ្ឋកិច្ច។ បុគ្គលស្រឡាញ់ភេទដូចគ្នាជាច្រើនជ្រើសរើសការរស់នៅដោយលាក់បាំង ដើម្បីគេចពីភាពភ័យខ្លាចនៃការនាំឱ្យមានភាពអាម៉ាស់ដល់ក្រុមគ្រួសារ និងបាត់បង់ការគាំទ្រផ្នែកហិរញ្ញវត្ថុ។ អ្នកដែលសម្រេចចិត្តបង្ហាញអត្តសញ្ញាណភេទ ឬយេនឌ័ររបស់ពួកគេភាគច្រើនត្រូវបានគ្រួសារបណ្តេញចេញ ឬបង្ខំឱ្យរៀបការជាមួយមនុស្សភេទផ្ទុយ ហើយក្នុងករណីខ្លះ ធ្លាប់ទទួលការព្យាបាលរោគវិកលចរិក ឬហៅថា" ការព្យាបាលរំដោះគ្រោះ" ដោយគ្រូខ្មែរព្យាបាលតាមបែបបុរាណ ដូចដែលបានគូសបញ្ជាក់នៅក្នុងរបាយការណ៍ UNDP និង USAID ឆ្នាំ២០១៤។

---

[24] Kunthear, M and Drennan, J. (2013). Laws can't stop lovers marrying. Phnom Penh Post, 20 May 2013. At: https://www.phnompenhpost.com/national/laws-can%E2%80%99t-stop-lovers-marrying

[25] Ibid.

[26] UNDP, USAID (2014). Being LGBTI in Asia: Cambodia Country Report. Bangkok. At: https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf

[27] Cambodia Center for Human Rights (CCHR). (2010). Coming Out in the Kingdom: Lesbian, Gay, Bisexual and Transgender People in Cambodia. p.16. At: https://cchrcambodia.org/admin/media/report/report/english/2010-12-09%20COMING%20OUT%20IN%20THE%20KINGDOM%20LESBIAN,%20GAY,%20BISEXUAL%20AND%20TRANSGENDER%20PEOPLE%20IN%20CAMBODIA_EN%20.pdf

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ពន្យល់បន្ថែមទៀតនៅក្នុងរបាយការណ៍ឆ្នាំ ២០១០ថា៖

*“ការបន្តទំនាក់ទំនងស្រឡាញ់ភេទដូចគ្នា គឺជាផ្លូវមួយដែលបុគ្គលភាគច្រើនមិនអាចមានលទ្ធភាពទទួលបានភាពសមរម្យនៅក្នុងសង្គម ឬសេដ្ឋកិច្ច។ ហានិភ័យនៃការបណ្តេញចេញពីគ្រួសារ និងការលំបាកផ្នែកសេដ្ឋកិច្ចបណ្តាលមកពីការរស់នៅតែម្នាក់ឯងអាចមានន័យថាអ្នកស្រឡាញ់ភេទដូចគ្នាមិនរស់នៅក្នុងជីវិតដែលពួកគេចង់បាន ឬត្រូវមានទំនាក់ទំនងស្រឡាញ់ភេទដូចគ្នាដោយលាក់បាំង។ ដូច្នេះការរស់រានផ្នែកសេដ្ឋកិច្ច និងភាពជាក់ស្តែងនឹងតែងតែឈ្នះលើការបង្ហាញអត្តសញ្ញាណផ្ទាល់ខ្លួន និងទំនោរភេទ”*[28]

[28] Ibid.

នៅក្នុងការស្ទង់មតិដែលធ្វើឡើងឆ្នាំ២០១៦ ដោយ MRIF នៅកម្ពុជា អ្នកចូលរួមទាំង ១៥នាក់ បានរាយការណ៍ថា បានទទួលរងនូវការរើសអើងពីក្រុមគ្រួសារ រាប់ចាប់ពី ការរំលោភបំពានដោយពាក្យសំដី ការសម្លុតមាក់ងាយ និងការគំរាមគំហែងមិនផ្តល់អាហារ ការចាប់បង្ខាំងនៅក្នុងផ្ទះ ឬបង្ខំឱ្យចាកចេញពីផ្ទះ ឬពីការងារ។[29] ការសិទ្រង់ទ្រាយធំជាច្រើនដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាក្នុងឆ្នាំ ២០១០ និងក្នុងឆ្នាំ ២០១៤ ដោយ UNDP ជាមួយទីភ្នាក់ងារ USAID ដែលមានអ្នកចូលរួមផ្សេងគ្នា ៦០នាក់ និង ៥៩នាក់ បញ្ជាក់ពីបទពិសោធន៍ទូទៅនៃអំពើហឹង្សាក្នុងគ្រួសារដោយសមាជិកគ្រួសារ រួមមាន ការរំលោភបំពានលើរាងកាយ និងផ្លូវចិត្ត ការបដិសេធ ការគំរាមកំហែង ការបង្ខាំងនៅក្នុងផ្ទះ ការបង្ខំឲ្យបែកគ្នាពីដៃគូ និងការបង្ខំឲ្យរៀបការ។

បញ្ហាប្រឈមធំមួយទៀតសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា គឺជាការពិតដែលមិនមានពាក្យជាភាសាខ្មែរដើម្បីពិពណ៌នាអំពីនិន្នាការភេទ មិនថាជាការស្រឡាញ់ភេទដូចគ្នា ឬភេទផ្ទុយគ្នា។ យោងតាមរបាយការណ៍ឆ្នាំ ២០០៨របស់អង្គការយូណេស្កូ "ទស្សនៈនៃយេនឌ័រ និងភេទ ហាក់ដូចជាមិនត្រូវបានគេសម្គាល់បែងចែងអោយច្បាស់ទេ ហើយអត្តសញ្ញាណរបស់មនុស្សម្នាក់ នឹងត្រូវបានកំណត់ដោយផ្អែកលើភេទពីកំណើតរបស់ពួកគេ (ប្រុស ឬស្រី) ឬក៏ដោយការបង្ហាញយេនឌ័ររបស់ពួកគេ (ភាពជាស្រ្តី ឬជាបុរស)"។[30] ការមិនរាប់បញ្ចូលភាសានៃភេទបែបនេះ ហាក់ដូចជាមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការយល់ដឹងរបស់សង្គមអំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា ទោះបីជាសកម្មជនក្នុងរយៈពេលជាងពីរទសវត្សចុងក្រោយនេះ បានធ្វើការប្រឈមជាមួយនឹងបទដ្ឋានកំណត់យេនឌ័រគោលពីរ (និងការស្រឡាញ់ភេទផ្ទុយគ្នា) នៅក្នុងការជជែកពិភាក្សាអំពីសុខភាពផ្លូវភេទ និងសិទ្ធិមនុស្សក៏ដោយ។

ការអបអរសាទរទិវាមោទនភាពរបស់ប្រទេសកម្ពុជា បានចាប់ផ្តើមដំបូងក្នុងឆ្នាំ ២០០៣ ហើយសកម្មជនបានកើនឡើងច្រើនក្នុងការរៀបចំចាប់តាំងពីពេលនោះមក។ ទោះបីជាអង្គការសិទ្ធិមនុស្សទូទៅ និងអង្គការអ្នកស្រឡាញ់ភេទដូចគ្នាមិនផ្លូវការបាន និងកំពុងធ្វើការលើបញ្ហាទាំងនេះជាបណ្តោះអាសន្នក៏ដោយ ដល់ឆ្នាំ ២០១៤ មានការចុះឈ្មោះជាផ្លូវការដំបូងនៃអង្គការអ្នកស្រឡាញ់ភេទដូចគ្នាជាអង្គការក្រៅរដ្ឋាភិបាលមួយហៅ សហគមន៍ឥន្ទធនូកម្ពុជា (RoCK)[31]។ នៅក្នុឆ្នាំដដែលប្រទេសនេះបានធ្វើកិច្ចសន្ទនាសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាថ្នាក់ជាតិលើកដំបូងរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ហើយលើកទី២ ធ្វើឡើងនៅឆ្នាំ ២០១៩ ។[32] ក្នុងកិច្ចពិភាក្សាលើកទី២នេះ រដ្ឋលេខាធិការ ឯ.ឧ កែវ រេមី បានប្តេជ្ញាចិត្តជាសាធារណៈដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាដោយទទួលយកនូវអនុសាសន៍ទាំង៩ ចំណុចទាក់ទងនឹងសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា នៃការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់(UPR)ជុំទី៣។ សកម្មជន អ្នកធ្វើយុទ្ធនាការ និងអ្នកតស៊ូមតិបច្ចុប្បន្ន កំពុងស្នើសុំរដ្ឋាភិបាលឱ្យដាក់បញ្ចូលក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងសេចក្តីព្រាងច្បាប់អត្រានុកូលដ្ឋានថ្មីដែលផ្តល់ការចុះបញ្ជីសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព ហើយនិង អនុវត្តផែនការសកម្មភាពឆ្លើយតបទៅនឹងតម្រូវការអាទិភាពសម្រាប់ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា។ រដ្ឋាភិបាលបានបង្ហាញការគាំទ្រ និងបង្ហាញឆន្ទៈក្នុងការសហការជាមួយសង្គមស៊ីវិល ប៉ុន្តែបានសង្កត់ធ្ងន់ថាវាអាចត្រូវការពេលព្រោះមានកិច្ចការចាំបាច់បន្ថែមច្រើនទៀតដើម្បីធ្វើការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេស។

អ្នកចូលរួមក្នុងក្រុមពិភាក្សាបានទទួលស្គាល់ថាស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាមានភាពប្រសើរឡើងច្រើននាពេលបច្ចុប្បន្ននេះ។ រដ្ឋាភិបាលកម្ពុជា

---

29 Chhoeurng, Rachana; Kong, Yara; Power, Erin. (2016). Poverty of LGBT people in Cambodia, p. 17London, UK: Micro Rainbow International C.I.C. At: https://microrainbow.org/wp-content/uploads/2017/12/CambodiaReportEN.pdf

30 UNESCO (2008). HIV/AIDS Prevention Programme: Ethnography of Male to Male Sexuality in Cambodia. Phnom Penh. At: http://unesdoc.unesco.org/images/0016/001630/163077E.pdf

31 Rainbow Community Kampuchea (RoCK). At: http://www.rockcambodia.org/?page=detail&menu1=224&menu2=273&ctype=article&id=273&lg=en

32 (RoCK), MRIF. (2019). Second National Dialogue on Legal and Public Policies to Protect LGBTIQ People in Cambodia. Joint Press Release. 27 June 2019. Phnom Penh. At: https://cchrcambodia.org/media/files/press_release/716_fprpde_en.pdf?fbclid=IwAR1EXzAMx6-oofncSAus0xfkOMrbig8EkmYewNUBsLbpYefl-L_YQsAJRxc

បានចាប់ផ្ដើមបង្ហាញការគាំទ្រច្រើន ចំពោះបុព្វហេតុនេះ ហើយចំនួនអង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងសម្ព័ន្ធមិត្តបានកើនឡើង។ ដូចគ្នានេះផងដែរមានការកើនឡើងនូវព័ត៌មានវិជ្ជមានអំពីបញ្ហាអ្នកស្រលាញ់ភេទដូចគ្នាតាមរយៈបណ្ដាញផ្សព្វផ្សាយសង្គម ហើយមានចំនួនអ្នកស្រឡាញ់ភេទដូចគ្នាហាក់ដូចជាកំពុងចេញមុខជាចំហច្រើនដែរ។

ទោះយ៉ាងណាទន្ទឹមនឹងនេះនៅតែមានទម្រង់នៃអំពើហឹង្សា និងការរើសអើងជាច្រើនបានកើតឡើងជារៀងរាល់ថ្ងៃចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា ហើយសង្គមទាំងមូលដោយផ្ដោតលើបទដ្ឋានកំណត់យេនឌ័រពីរ និងគ្រួសារផ្ដោតការស្រឡាញ់ភេទផ្ទុយគ្នាតែម្យ៉ាង រារាំងមនុស្សពីការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា។

**ទម្រង់អំពើហឹង្សា និងការរើសអើងរួមភាគច្រើនដែលអ្នកចូលរួមបានជួបប្រទះគឺ៖**

- ការរើសអើងដោយគ្រួសារ សហគមន៍ និងអាជ្ញាធរមូលដ្ឋានមួយចំនួន
- កង្វះនូវយន្តការដើម្បីរាយការណ៍ពីអំពើហឹង្សា និងការរើសអើង
- ខ្វះនូវការគាំទ្រពីអាជ្ញាធរមូលដ្ឋាន
- មិនទាន់មានច្បាប់ការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា
- ការបកស្រាយខុស និងការយល់ច្រឡំនៃអត្តសញ្ញាណអ្នកស្រឡាញ់ភេទដូចគ្នាដោយសង្គមភាគច្រើន។ ដូចដែលបានលើកឡើងដោយអ្នកចូលរួមជាច្រើននាក់ថា *"យើងជាខ្មោចព្រាយបិសាចអាក្រក់នៅក្នុងផ្នត់គំនិតប្រជាពលរដ្ឋកម្ពុជា"*។

*"យើងជាខ្មោចព្រាយបិសាចអាក្រក់នៅក្នុងផ្នត់គំនិតប្រជាពលរដ្ឋកម្ពុជា"*

## ៥. បទពិសោធន៍ជីវិត៖ ការផាត់ចេញអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងវិស័យសេដ្ឋកិច្ច នៅកម្ពុជា

### ការងារ សហគ្រិនភាព និងសេវាកម្មហិរញ្ញវត្ថុ ការអប់រំ និងសុខភាពការងារ

មិនមានច្បាប់ប្រឆាំងនឹងការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា នៅកន្លែងធ្វើការនោះទេ។ ប្រជាជនកម្ពុជាដែលមិនគោរពតាមការបង្ហាញ និងកំណត់អត្តសញ្ញាណនូវបទដ្ឋាននៃការស្រឡាញ់ភេទផ្ទុយគ្នា ប្រឈមនឹងឧបសគ្គជាច្រើនក្នុងទីផ្សារការងារ៖ ពីការរើសអើង និងការបដិសេធក្នុងដំណើរការដាក់ពាក្យសុំការងារទាំងការបៀតបៀន និងការសម្លុតធ្វើបាបនៅកន្លែងធ្វើការ។ អ្នកស្រឡាញ់ភេទដូចគ្នាដែលចូលរួមក្នុងការសិក្សារបស់ មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) ឆ្នាំ ២០១៦ បានបង្ហាញថាពួកគេត្រូវបានអ្នកផ្សេងប្រើប្រាស់ពាក្យសំដីមិនសមរម្យនៅកន្លែងធ្វើការ ដោយបុគ្គលិករួមការងារបច្ចុប្បន្ន និងពីមុនៗ ហើយត្រូវបានប្រាប់ឱ្យផ្លាស់ប្តូរអាកប្បកិរិយា និងការស្លៀកពាក់ចេញ។[33]

ទាំងនេះអាចពន្យល់ពីមូលហេតុដែលអ្នកស្រឡាញ់ភេទដូចគ្នា មិនមានអារម្មណ៍កក់ក្តៅក្នុងការបង្ហាញអំពីទំនោរភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគាត់នៅកន្លែងធ្វើការ ដូចដែលបានបង្ហាញក្នុងរបាយការណ៍របស់ UNDP និង USAID ឆ្នាំ ២០១៤។ របាយការណ៍នេះបានអះអាងថា ដោយសារមានការរើសអើងជាច្រើននៅកន្លែងធ្វើការ និងកង្វះនូវគោលនយោបាយរបស់រដ្ឋាភិបាល និងក្រុមហ៊ុនដែលដោះស្រាយភាពចម្រុះ និងការដាក់បញ្ចូល មានឱកាសការងារតិចតួចសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសអ្នកមានកម្រិតការអប់រំទាបដែលងាយងាកទៅប្រកបរបររកស៊ីផ្លូវភេទដើម្បីរកចំណូល។ ទោះយ៉ាងណាការប្រកបរបររកស៊ីផ្លូវភេទគឺជាទង្វើខុសច្បាប់នៅក្នុងប្រទេសកម្ពុជា។

នេះជាករណីសម្រាប់អ្នកប្តូរយេនឌ័រជាស្ត្រីជាច្រើនដែលមានឱកាសការងារផ្លូវការ គឺបានកំណត់មកត្រឹម ក្នុងវិស័យសំអាង និងការកម្សាន្ត។ ទោះយ៉ាងណាក៏ដោយ សូម្បីតែអ្នកដែលធ្វើការជាអ្នកផ្តល់សេវាកម្សាន្តក៏អាចរងគ្រោះដោយសារការរំលោភបំពានបន្ថែមទៀតផងដរ។ មានសេចក្តីរាយការណ៍ពីអ្នកប្តូរយេនឌ័រជាស្ត្រីនៅក្នុងខេត្តសៀមរាប សូម្បីជាអ្នកធ្វើការងារសម្តែងនៅតាមហាងភោជនីយដ្ឋានផ្សេងៗក៏ដោយ ក៏មិនត្រូវបានអនុញ្ញាតឱ្យដើរនៅក្នុងតំបន់ទេសចរណ៍សំខាន់ៗដែរ ពីព្រោះពួកគេត្រូវបានគេសន្មតថាជាចោរ ហើយអាចត្រូវបានចាប់ខ្លួនដោយអាជ្ញាធរមូលដ្ឋាន។[34] អ្នកប្តូរយេនឌ័ជាស្ត្រីដែលប្រកបរបររកស៊ីផ្លូវភេទ គឺជាមុខសញ្ញារបស់ប៉ូលីសក្នុងការរំលោភបំពាន សូកប៉ាន់ ការកេងប្រវ័ញ្ច និងការចាប់ឃាត់ខ្លួនដោយចៃដន្យផងដែរ។ ការស្រាវជ្រាវបង្ហាញថា បន្ទាប់ពីរដ្ឋាភិបាលបានអនុម័តច្បាប់ឆ្នាំ ២០០៨ ស្តីពីការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ[35] ការចាប់ឃាត់ខ្លួនអ្នកប្តូរយេនឌ័រជាស្ត្រី និងបុរសរួមភេទជាមួយបុរស បានកើនឡើងចំនួន៣ដង ទាំងនោះធ្វើអោយមានការថយចុះនូវឱកាសរកប្រាក់ចំណូល ក៏ដូចជាការទទួលបានសេវាសុខភាព និងសេវាសង្គមរបស់ពួកគេ។[36]

នៅក្នុងប្រទេសមួយដែលមានប្រជាជន ៣៥ ភាគរយជាទូទៅរស់នៅក្នុងភាពក្រីក្រ និងអសន្តិសុខការងា[37] ការធានាឱកាសការងារ និងការបង្កើតប្រាក់ចំណូល

[33] Chhoeurng, Rachana; Kong, Yara; Power, Erin. (2016). Poverty of LGBT people in Cambodia. London, UK: Micro Rainbow International C.I.C. At: https://microrainbow.org/wp-content/uploads/2017/12/CambodiaReportEN.pdf

[34] UNDP, USAID (2014). Being LGBTI in Asia: Cambodia Country Report. Bangkok. At: https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf

[35] Cambodia: Law on Suppression of Human Trafficking and Sexual Exploitation.2008. At: https://www.unodc.org/res/cld/document/khm/2008/law_on_suppression_of_human_trafficking_and_sexual_exploitation_html/Cambodia_03_-_Law-on-Suppression-of-Human-Trafficking-and-Sexual-Exploitation-15022008-Eng.pdf

[36] Cambodian Alliance for Combatting HIV and AIDS (CACHA) & National AIDS Authority. (2009). Research Report: “Policies environment regarding universal access and the right to work of Entertainment Workers in Cambodia”. pp. 65–67 At: http://www.hacccambodia.org/download_pub.php?file=CACHA%20Action%20Research%20final_English%20version.pdf

[37] Oxford Poverty and Human Development Initiative (2018). Global Multidimensional Poverty Index 2018: The Most Detailed Picture to Date of the World’s Poorest People, University of Oxford, UK. At: https://ophi.org.uk/multidimensional-poverty-index/global-mpi-2018/

សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI) អាចជាបញ្ហាប្រឈមចម្បងផ្នែកសេដ្ឋកិច្ចសង្គម ប៉ុន្តែវាក៏ជាគន្លឹះក្នុងការកាត់បន្ថយការរើសអើង និងទទួលបានសមភាពផងដែរ។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាលើកដំបូងដែលបានធ្វើឡើងក្នុងឆ្នាំ ២០១៤ បានរាយការណ៍ថា ពួកគេមានអារម្មណ៍ថាមានសិទ្ធិអំណាច និងមានការទទួលស្គាល់កាន់តែខ្លាំងឡើងពីក្រុមគ្រួសារ និងសហគមន៍នៅពេលដែលស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេមានភាពប្រសើរ និងពេលពួកគេអាចរកប្រាក់បានកាន់តែច្រើនឡើង។[38] នេះត្រូវបាបញ្ជាក់ដោយការសិក្សារបស់មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) ឆ្នាំ ២០១៦ ដែលបានសន្និដ្ឋានថា៖

> *អ្នកស្រឡាញ់ភេទដូចគ្នាកាន់តែច្រើន ដែលឈានជើងចេញពីភាពក្រីក្រ ហើយក្លាយជាសមាជិកសំខាន់ និងមានឥទ្ធិពល នៃគ្រួសារ និងសហគមន៍របស់ពួកគេនោះការផ្លាស់ប្តូរឥរិយាបទកាន់តែទូលំទូលាយ*[39]

ចាប់តាំងពីឆ្នាំ ២០១៣ មក មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) បាននិងកំពុងអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា ដែលសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI) ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីផ្តួចផ្តើមសកម្មភាពបង្កើតប្រាក់ចំណូល។ មនុស្សជាច្រើនដែលធ្លាប់ត្រូវបានបដិសេធដោយក្រុមគ្រួសារ បានកត់សម្គាល់ឃើញមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងការទទួលយកពីសង្គម និងការគោរពចំពោះអត្តសញ្ញាណនៃភេទ យេនឌ័រ និងសេចក្តីស្រឡាញ់របស់ពួកគេបន្ទាប់ពីពួកគេបានចាប់ផ្តើមអាជីវកម្មខ្នាតតូចផ្ទាល់ខ្លួន ហើយអ្នកខ្លះថែមទាំងអាចបង្កើតចំណងគ្រួសារឡើងវិញ និងជួយគាំទ្រទៅដល់សាច់ញាតិរបស់ពួកគេ។[40]

រហូតមកដល់ខែកញ្ញាឆ្នាំ ២០១៩ មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) បានគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ចំនួន៧០នាក់អោយចាកចេញពីភាពក្រីក្រ ហើយ៣១នាក់ អាចចាប់ផ្តើមអាជីវកម្មខ្នាតតូចផ្ទាល់ខ្លួន និងបង្កើនប្រាក់ ចំណូល។ មនុស្ស២០នាក់បានទទួលប្រាក់កម្ចីខ្នាតតូច ដោយសារភាពជាដៃគូជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងស្រុក។ ៣៥នាក់ បានរាយការណ៍ពីការកើនឡើងនៃការទទួលស្គាល់ក្នុងសង្គម និងការគាំទ្រគ្រួសារបន្ទាប់ពីក្លាយ ជាម្ចាស់អាជីវកម្ម។ នៅក្នុងសង្គមដែលផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើទំនាក់ទំនងគ្រួសារ ការពង្រឹងអំណាចសេដ្ឋកិច្ចរបស់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) បានបង្ហាញថាជាមធ្យោបាយដ៏មានប្រសិទ្ធិភាពមួយ សម្រាប់ការកាត់បន្ថយការបដិសេធមិនរាប់បញ្ចូល និងការបាត់បង់ឱកាសនៃក្រុមភេទ និងយេនឌ័រភាគតិច ការផ្លាស់ប្តូរតម្លៃសង្គមអភិរក្សនិយម និងការប្រឈមនឹងបទដ្ឋាននៃការស្រលាញ់ភេទផ្ទុយគ្នា។

## ប្រភេទការងារអ្នកស្រឡាញ់ភេទដូចគ្នាបានធ្វើ

អ្នកចូលរួមនៃការពិភាក្សាជាក្រុម ត្រូវបានស្នើសុំឱ្យរាយឈ្មោះវិស័យនានា នៅក្នុងទីផ្សារការងារដែលអ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI) បានធ្វើការ និងចែករំលែកបទពិសោធន៍របស់ពួកគេ។ ពួកគេបានឆ្លើយដូចតទៅ៖

- អ្នកស្រឡាញ់ទាំងពីរភេទ៖ អ្នកម៉ាស្សា ជាងកាត់សក់ សិល្បៈករ អ្នកតំណាងផ្នែកលក់ បុគ្គលិកសណ្ឋាគារ បុគ្គលិកបារ និងក្លឹប អ្នករត់តុ
- បុរសស្រឡាញ់ភេទដូចគ្នា៖ វេជ្ជបណ្ឌិត មន្ត្រីរាជការ បុគ្គលិកអង្គការ អ្នករចនា អ្នកម៉ាស្សា ជាងផាត់មុខ សិល្បៈករ អ្នករត់តុ អ្នកធ្វើការសំណង់
- អ្នកប្តូរយេនឌ័រជាបុរស៖ អ្នកធ្វើការសំណង់ កសិករ រត់តុកៗ ឬឡានតាក់ស៊ី
- អ្នកប្តូរយេនឌ័រជាស្ត្រី៖ អ្នករកស៊ីផ្លូវភេទ ជាងអ៊ុតសក់ គ្រូបង្រៀន អ្នកលក់ម្ហូបអាហារ អ្នកម៉ាស្សា សិល្បៈករ បុគ្គលិកអង្គការ
- ស្ត្រីស្រឡាញ់ភេទដូចគ្នា៖ គ្រូបង្រៀន វេជ្ជបណ្ឌិត ជាងកាត់សក់ ស្ថាបត្យករ វិស្វករ

[38] UNDP, USAID (2014). Being LGBTI in Asia: Cambodia Country Report. Bangkok. At: https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf
[39] Chhoeurng, Rachana; Kong, Yara; Power, Erin. (2016). Poverty of LGBT people in Cambodia, p. 24. London, UK: Micro Rainbow International C.I.C. At: https://microrainbow.org/wp-content/uploads/2017/12/CambodiaReportEN.pdf
[40] Micro Rainbow International (2018). A wave of LGBTI acceptance in Cambodia. At: https://mrifoundation.global/a-wave-of-lgbti-acceptance-in-cambodia/

គណនេយ្យករ អ្នកតំណាងផ្នែកលក់ ចុងភៅ បុគ្គលិកធនាគារ បុគ្គលិកអង្គការ អ្នករត់តុ អ្នកគ្រប់គ្រង ប៉ូលីស ទាហាន

## បញ្ហាប្រឈមក្នុងការស្វែងរកឱកាសការងារ

នៅពេលដែលអ្នកចូលរួមត្រូវបានសួរ ឱ្យរៀបរាប់អំពីបញ្ហាប្រឈម ដែលពួកគេបានជួបប្រទះក្នុងដំណើរការទទួលបានឱកាសការងារ ពួកគេមានចម្លើយជាឯកច្ឆន្ទថាអត្តសញ្ញាណនៃភេទ យេនឌ័រ និងការស្រឡាញ់របស់ពួកគេ គឺជាឧបសគ្គដ៏ធំ ហើយការរើសអើងពីនិយោជក ឬអតិថិជនគឺជាបទពិសោធន៍ជួបជាទូទៅ។ សម្រាប់បុគ្គលខ្លះការមិនមានជំនាញគ្រប់គ្រាន់ ក៏ជាឧបសគ្គក្នុងជីវិតអាជីពរបស់ពួកគេដែរ។

សម្រាប់អ្នកចូលរួមដែលជាអ្នកស្រឡាញ់ទាំងពីរភេទ គឺពិបាករកការងារធ្វើណាស់ ប្រសិនបើពួកគេបង្ហាញពីការស្រឡាញ់ទាំងពីរភេទរបស់ពួកគេ។ ៤នាក់ក្នុងចំណោម អ្នកចូលរួមមានបញ្ហាក្នុងការស្វែងរកឱកាសការងារដោយសារតែខ្វះចំណេះដឹងភាសាបរទេស និងជំនាញផ្សេងទៀត។ ៤នាក់ ក្នុងចំណោមបុរសស្រឡាញ់បុរស ត្រូវលាក់ការស្រឡាញ់ភេទដូចគ្នាដើម្បីស្វែងរកការងារធ្វើ ហើយ៤នាក់ទៀតមិនត្រូវបានគេទទួលស្គាល់ ឬគេមិនគោរពនៅកន្លែងធ្វើការរបស់ពួកគេដោយសារតែការស្រឡាញ់ភេទដូចគ្នា។ ២នាក់ បានបង្ហាញថាពួកគេបានរងការរំលោភបំពានពីអតិថិជន (ពួកគេត្រូវបានបង្ខំឱ្យរួមភេទ ឬរងគ្រោះដោយសារការរំលោភបំពានលើរូបរាងកាយ) និង៦នាក់ បានសារភាពថាពួកគេមិនអាចរកការងារធ្វើបានទេ ពីព្រោះពួកគេមិនមានជំនាញគ្រប់គ្រាន់។ អ្នកចូលរួមដែលជាស្ត្រីស្រឡាញ់ភេទដូចគ្នាទាំងអស់បានរាយការណ៍ពីការលំបាកក្នុងការស្វែងរកការងារធ្វើដោយសារកង្វះជំនាញ និងការរើសអើងពីគ្រួសារដែលធ្វើឱ្យពួកគេបាត់បង់នូវទំនុកចិត្ត និងសេចក្តីប្រាថ្នានៃការងារ។

អ្នកប្តូរយេនឌ័រជាស្ត្រីទាំងអស់ បានរាយការណ៍អំពីបញ្ហាក្នុងការទទួលបានឱកាសការងារ និងរក្សាការងារ។ ពួកគេទាំងអស់តស៊ូលំបាកក្នុងការស្វែងរកការងារធ្វើ ដោយសារតែការរើសអើងអ្នកប្តូរយេនឌ័រ ហើយពួកគេទាំងអស់បានប្រឈមមុខនឹងការរើសអើងយ៉ាងធ្ងន់ធ្ងរនៅអំឡុងពេលពួកគេធ្វើការងារមិនថានៅក្នុងស្ថាប័នឯកជន ឬស្ថាប័នសាធារណៈ។ អ្នកប្តូរយេនឌ័រជាស្ត្រីអាយុ ៣១ឆ្នាំម្នាក់បានប្រាប់ពួកយើងថា "និយោជកតែងតែបញ្ឈប់ការសម្ភាស នៅពេលពួកគេដឹងថាខ្ញុំជាអ្នកប្តូរយេនឌ័រជាស្ត្រី" ។ សម្រាប់អ្នកប្តូរយេនឌ័រជាបុរស គឺមានស្ថានភាពស្រដៀងគ្នាផងដែរ ពួកគេទាំងអស់ត្រូវបានរើសអើងដោយនិយោជក ហើយមិនមានបរិយាកាសសុវត្ថិភាព និងការទទួលស្គាល់នៅកន្លែងធ្វើការទេ។

## ការប្រព្រឹត្តចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកន្លែងធ្វើការ

នៅពេលដែលអ្នកចូលរួមត្រូវបានសួរអំពីរបៀបនៃការទទួល ឬប្រព្រឹត្តទៅកាន់ពួកគេ នៅក្នុងកន្លែងធ្វើការ គឺបានបង្ហាញថាពួកគេមានបទពិសោធមិនល្អនៅក្នុងកន្លែងធ្វើការ ដោយគ្រាន់តែគេជាមនុស្សស្រឡាញ់ភេទដូចគ្នាម្នាក់។

អ្នកចូលរួមដែលជាអ្នកស្រឡាញ់ទាំងពីរភេទ និងស្ត្រីស្រឡាញ់ភេទដូចគ្នា មានទស្សនៈ និងបទពិសោធន៍ប្រហាក់ប្រហែលគ្នា ដរាបណាពួកគេមិនបានបង្ហាញពីទំនោរភេទរបស់ពួកគេ គឺមិនមានបញ្ហានោះទេ។ បើមិនដូច្នោះទេ ពួកគេអាចប្រឈមនឹងហានិភ័យនៃការបាត់បង់ការងារ។ អ្នកចូលរួមជាស្ត្រីស្រលាញ់ភេទដូចគ្នាបាននិយាយថា នៅពេលអ្នកដទៃដឹងអំពីអត្តសញ្ញាណរបស់ពួកគេ ជាធម្មតាត្រូវគេប្រមាថមើលងាយ ឬត្រូវបានគេសួរដេញដោលនូវសំណួរពាក់ព័ន្ធឯកជនភាពផ្ទាល់ខ្លួន។ អ្នកចូលរួមដែលជាបុរសស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រជាបុរសទាំងអស់បានបង្ហាញថា ពួកគេបានប្រឈមដោះស្រាយជាមួយនឹងបរិយាកាសការងារដែលមានភាពពិបាកស្មុកស្មាញខ្លាំង ទាំងដែលនិយោជកនឹងមិនទុកចិត្តពួកគេ ឬអ្នករួមការងាររបស់ពួកគេនឹងមិនធ្វើល្អចំពោះពួកគេឡើយ។ សម្រាប់អ្នកប្តូរយេនឌ័រជាស្ត្រីជាការពិតក៏មានលក្ខណៈអាក្រក់ផងដែរ ១០នាក់ត្រូវបានគេជេរប្រមាថមើលងាយនៅកន្លែងធ្វើការ និង៧នាក់ទទួលរងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ។

> **“ យើងអាចបើកអាជីវកម្ម ប៉ុន្តែយើងមិនមានលុយ និងជំនាញដើម្បីចាប់ផ្តើមទេ ”**

## ការងារ សហគ្រិនភាព និងសេវាកម្មហិរញ្ញវត្ថុ

នៅពេលអ្នកចូលរួមត្រូវបានសួរថា តើអ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI) អាចបើកអាជីវកម្មផ្ទាល់ខ្លួនបានទេ? ពួកគេទាំងអស់និយាយថា អាចបាន ប៉ុន្តែបានបញ្ជាក់ថាពួកគេមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ទេ។ ម្នាក់ក្នុងចំណោមពួកគេបានសង្កត់ធ្ងន់ថា

*“យើងអាចបើកអាជីវកម្ម ប៉ុន្តែយើងមិនមានលុយ និងជំនាញដើម្បីចាប់ផ្តើមទេ”* ។

ការខ្វះខាតលុយកាក់ គឺជាប្រធានបទរួមដែលបានឆ្លើយតបទាំងអស់គ្នា នៅពេលដែលអ្នកចូលរួមក្នុងក្រុមពិភាក្សា ទាំង៣២នាក់ត្រូវបានគេសួរថា តើបញ្ហាហិរញ្ញវត្ថុប្រភេទណាដែលពួកគេប្រឈមមុខ។

អ្នកចូលរួមដែលជាអ្នកស្រឡាញ់ទាំងពីរភេទទាំងអស់បានរាយការណ៍ថា ពួកគេជួបការលំបាកផ្នែកហិរញ្ញវត្ថុ និងមិនមានឱកាសការងារគ្រប់គ្រាន់ ឬមិនមានប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់គ្រួសារដៃគូ ឬខ្លួនគេផ្ទាល់។ អ្នកចូលរួមដែលជាបុរសស្រលាញ់ភេទដូចគ្នាទាំងអស់បានបង្ហាញថា ពួកគេមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីចាប់ផ្តើមអាជីវកម្មទេ ហើយ៥នាក់បាននិយាយថា ពួកគេមិនបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីគ្រួសាររបស់ពួកគេទេ។ ស្ត្រីស្រលាញ់ភេទដូចគ្នាទាំងអស់មានចម្លើយប្រហាក់ប្រហែលគ្នា ពួកគេរកប្រាក់ចំណូលបានតិចតួចណាស់ ហើយមិនអាចបំពេញការចំណាយក្នុងការរស់នៅបានទេ។ ពួកគេបាននិយាយថា ពួកគេមិនអាចរកបានឱកាសការងារល្អប្រសើរជាងមុនដោយសារតែខ្វះជំនាញ ឬចំណេះដឹង។

អ្នកប្តូរយេនឌ័រជាបុរសទាំងអស់បានរាយការណ៍ពីប្រាក់ចំណូលទាប និងបាននិយាយថាពួកគេមិនអាចបំពេញការចំណាយជាមូលដ្ឋាន ដូចជាការជួលផ្ទះ វិក័យប័ត្រចំណាយ និងការថែទាំសុខភាព។ ពួកគេបួននាក់បាននិយាយថា ពួកគេមិនមានប្រាក់គ្រប់គ្រាន់ដើម្បីសងបំណុលរបស់ពួកគេទេ។ ក្នុងចំណោមអ្នកប្តូរយេនឌ័រជាស្ត្រី១០នាក់ បានប្រាថ្នាអោយពួកគេមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីចាប់ផ្តើមអាជីវកម្ម ហើយ៧នាក់ជឿថាពួកគេមិនមានជំនាញគ្រប់គ្រាន់ក្នុងការស្វែងរកការងារល្អជាងនេះទេ។ ស្រដៀងគ្នានេះដែរ ចំពោះអ្នកប្តូរយេនឌ័រជាបុរស ចំនួន១១នាក់បានបង្ហាញថា ពួកគេមិនអាចបំពេញការចំណាយក្នុងការរស់នៅជាមូលដ្ឋានប្រចាំថ្ងៃបានទេ។

អ្នកចូលរួមត្រូវបានសួរថា តើនិន្នាការភេទ ឬអត្តសញ្ញាណ និងការបង្ហាញយេនឌ័ររបស់ពួកគេបានប៉ះពាល់ដល់សមត្ថភាពក្នុងការសន្សំប្រាក់ដែរឬទេ។ ភាគច្រើននៃអ្នកចូលរួម (៣០ នាក់) បានយល់ស្របថាជាលទ្ធផលនៃការរើសអើងដែលពួកគេបានប្រឈមមុខនៅកន្លែងធ្វើការ ឬនៅក្នុងប្រព័ន្ធអប់រំពួកគេមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ ឬមានការងារដែលមានប្រាក់ខែគ្រប់គ្រាន់ដើម្បីអាចឱ្យពួកគេសន្សំប្រាក់បាន។ បុរសស្រឡាញ់ភេទដូចគ្នាអាយុ ៣៥ឆ្នាំម្នាក់បាននិយាយថា “ខ្ញុំមិនមានលុយទេ តើខ្ញុំអាចសន្សំបានយ៉ាងដូចម្តេច?” ។ អ្នកផ្សេងទៀតបាននិយាយថា ពួកគេមិនបានមើលឃើញពីចំណុចនៃការសន្សំប្រាក់ទេ ប្រហែលជាដោយសារតែពួកគេរស់នៅក្នុងភាពក្រីក្រហើយមានតម្រូវការ និងអាទិភាពបន្ទាន់ផ្សេងទៀត។

អ្នកចូលរួមបានពិភាក្សាអំពីបញ្ហាប្រឈមដែលពួកគេបានជួបប្រទះ ក្នុងការទទួលបានសេវាធនាគារជាទូទៅ។ បញ្ហាប្រឈមចម្បងសម្រាប់អ្នកចូលរួមទាំងអស់គឺការអោយបានទទួលប្រាក់កម្ចីពីធនាគារព្រោះពួកគេមិនមានឯកសារចាំបាច់ (អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ[41] សំបុត្រកំណើត និង/ឬលិខិតបញ្ជាក់អាសយដ្ឋាន) ឬដោយសារមិនមានអ្នកធានា។ ឧបសគ្គដូចគ្នាត្រូវបានប្រឈមមុខខណៈពេលព្យាយាមទទួលបានការធានារ៉ាប់រង ឬឥណទានដើម្បីបើកអាជីវកម្ម។

[41] A family book is an official document holder which contains copies of marriage and birth certificates etc. Usually given to couples when they marry, or to unmarried couples when their first child is born.

## ការអប់រំ

យុវជនអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាច្រើន តែប្រឈមនឹងបញ្ហាជាច្រើន ក្នុងពេលដែលពួកគេទៅទទួលការអប់រំជាផ្លូវការ ដែលអាចរារាំងឱកាសរបស់ពួកគេក្នុងការទទួលបានឱកាសការងារសមរម្យ និងទទួលបានប្រាក់ចំណូលគ្រប់គ្រាន់។ ដោយសារសីលធម៌ដ៏តឹងរឹងរបស់ប្រទេសនេះផ្អែកលើបទដ្ឋានយេនឌ័រគោលពីរ (យេនឌ័របុរស និងស្ត្រី) កុមារដែលជាអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ត្រូវបានក្រុមគ្រួសារ និងគណៈគ្រប់គ្រងសាលារៀនបង្ខំឲ្យមានឥរិយាបថ និងស្លៀកពាក់ស្របតាមជីវសាស្ត្រភេទរបស់ពួកគេ ហើយជារឿយៗពួកគេរងគ្រោះដោយការសម្លុតប្រមាថមើលងាយ និងការរើសអើងពីមិត្តរួមថ្នាក់។ ហេតុដូច្នេះហើយជាច្រើននាក់មិនបានបញ្ចប់ការសិក្សារបស់ពួកគេទេ ជាពិសេសសមាជិកនៃក្រុមអ្នកប្តូរយេនឌ័រ ដែលជារឿយៗងាកទៅរកការងារប្រកបរបររកស៊ីផ្លូវភេទដើម្បីចិញ្ចឹមជីវិត។

ភ័ស្តុតាងពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបង្ហាញពីអត្រាបោះបង់ការសិក្សាក្នុងចំណោមយុវជនអ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI) ដោយសារតែ “មិនត្រឹមតែការលំបាកខាងសេដ្ឋកិច្ចដែលបណ្តាលមកពីការមិនទទួលស្គាល់ដោយក្រុមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការហៅ និងការសម្លុតមើលងាយពីមិត្តរួមថ្នាក់ទាក់ទងនឹងភេទរបស់ពួកគេផងដែរ។”[42]

ទាំងនេះត្រូវបានបញ្ជាក់ដោយអ្នកចូលរួមក្នុងការសិក្សារបស់ MRIF ឆ្នាំ ២០១៦ ។ ៨៧ ភាគរយនៃអ្នកដែលបានសម្ភាសន៍មិនបានបញ្ចប់ការសិក្សារបស់ពួកគេទេ ហើយមានតែ ២ ភាគរយប៉ុណ្ណោះដែលទទួលបានសញ្ញាប័ត្រសាកលវិទ្យាល័យ។ នៅពេលត្រូវបានសួរថាហេតុអ្វីបានជាពួកគេមិនអាចបញ្ចប់ការសិក្សាបាន ៦២ភាគរយនិយាយថា ភាពក្រីក្រ ខណៈពេលដែលអ្នកផ្សេងទៀតនិយាយអំពីការរើសអើងដោយគ្រួសាររបស់ពួកគេ (ដែលឈប់បង់ថ្លៃការសិក្សា) ឬដោយអ្នកផ្សេងទៀតនៅសាលារៀន ឬនៅសាកលវិទ្យាល័យ (ដែលបានចូលរួមក្នុងការសម្លុតធ្វើបាប ឬរំលោភបំពានរាងកាយ)។[43]

របាយការណ៍ការផាត់ចេញពីសង្គម (Social Exclusion) ឆ្នាំ២០១៣ ពីមូលនិធិស្រាវជ្រាវការពារសង្គមកម្ពុជាបានបង្ហាញថា ៥២ភាគរយនៃអ្នកចូលរួមក្នុងការសិក្សាបានទទួលរងនូវការរើសអើងនៅក្នុងសាលារៀន ហើយមានតែ៤៣ភាគរយប៉ុណ្ណោះដែលបានចូលរៀននៅសាកលវិទ្យាល័យ (២០ភាគរយនៃបុរសស្រឡាញ់ភេទដូចគ្នា ១៧ភាគរយនៃស្ត្រីស្រឡាញ់ស្រឡាញ់ភេទដូចគ្នា និង៦ភាគរយនៃអ្នកប្តូរយេនឌ័រជាស្ត្រី)។ អ្នកចូលរួមក៏បានបង្ហាញពីការរកឃើញដ៏គួរឱ្យភ្ញាក់ផ្អើលផងដែរ៖ អ្នកប្តូរយេនឌ័រជាស្ត្រី ៣០ភាគរយ និងបុរសស្រឡាញ់ភេទដូចគ្នា ៧ភាគរយបានទទួលរងសម្ពាធពីក្រុមគ្រួសារឱ្យបញ្ឈប់ការសិក្សា ឬការងារ។[44] នេះបង្ហាញថាការទទួស្គាល់ពីគ្រួសារក៏ដើរតួយ៉ាងសំខាន់ ក្នុងការកំណត់កម្រិតអប់រំជាផ្លូវការរបស់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ហើយឪពុកម្តាយ និងសាច់ញាតិមួយចំនួននៅតែមានគំនិតរើសអើង និងយល់ច្រលំថាកូនចៅជាអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) នឹងនាំឱ្យមានការអាម៉ាស់អាប់ឱនដល់គ្រួសាររបស់ពួកគេ។ វាក៏បង្ហាញផងដែរថា ត្រូវការការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីលើកទឹកចិត្តដល់ភាពចម្រុះ និងការដាក់បញ្ចូលទៅក្នុងប្រព័ន្ធអប់រំនៅកម្ពុជា។

ជំហានសំខាន់មួយនៅក្នុងទិសដៅនេះ គឺត្រូវបានអនុវត្តនៅឆ្នាំ ២០១៥ នៅពេលដែល MRIF បានសហការជាមួយអង្គការក្នុងស្រុកមួយគឺ CamASEAN និងក្រសួងអប់រំ (មន្ទីរអប់រំយុវជន និងកីឡា) ក្នុងការបណ្តុះបណ្តាលគ្រូ និងគរុសិស្សស្តីពីបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៅក្នុងខេត្តចំនួន៩។ គ្រូសរុបចំនួន៣១០០នាក់ត្រូវបានបណ្តុះបណ្តាលនៅតាមសាលាចំនួន១៦ក្នុងប្រទេសកម្ពុជា។ ជាលទ្ធផលនៃកិច្ចសហការនេះ ក្នុងឆ្នាំ២០១៧ ក្រសួងបានអញ្ជើញសកម្មជនអ្នកស្រឡាញ់ភេទដូចគ្នា ចូលរួមដើម្បីបង្កើតកម្មវិធីសិក្សាស្តីពី សុខភាព

[42] Cambodia Center for Human Rights (CCHR). (2012). Rainbow Khmer: From Prejudice to Pride. At: https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=85&id=3

[43] Chhoeurng, Rachana; Kong, Yara; Power, Erin. (2016). Poverty of LGBT people in Cambodia. London, UK: Micro Rainbow International C.I.C. At: https://microrainbow.org/wp-content/uploads/2017/12/CambodiaReportEN.pdf

[44] Salas V & Srun S. (2013). An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities and their ways of coping. Research report. Social Protection Coordination Unit, Council for Agricultural Research and Development (SPCU-CARD), Phnom Penh

ផ្លូវភេទ និងការអប់រំសម្រាប់កម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ បច្ចុប្បន្នសម្ភារៈកំពុងត្រូវបានផលិត ហើយនឹងត្រូវបញ្ចូលក្នុងកម្មវិធីសិក្សានៅឆ្នាំ ២០២១ ។

មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) ណែនាំថា "ការអប់រំ គឺជាផ្លូវចេញពីភាពក្រីក្រ" ដូច្នេះហើយវាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបង្កើនលទ្ធភាពទទួលបានការអប់រំសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ដើម្បីឱ្យពួកគេអាចមានឱកាសការងារ និងលក្ខខណ្ឌរស់នៅល្អប្រសើរ៖

*"សម្រាប់អនាគតសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា ការអប់រំ គឺជាកត្តា សំខាន់ដែលជួយទាំងអ្នកស្រលាញ់ភេទដូចគ្នា ឲ្យស្ថិតនៅក្នុងប្រព័ន្ធអប់រំមួយដែលមានតម្លៃថ្លៃសម្រាប់ប្រជាជនភាគច្រើនដែលក្រីក្រ ហើយនិងធ្វើការផ្លាស់ប្តូរឥរិយាបថនៅក្នុងប្រព័ន្ធអប់រំ ដូច្នេះក្រុមអ្នកស្រឡាញ់ភេទដូចគ្នាមិនបោះបង់ចោលការសិក្សា នៅពេលពួកគេមិនអាចទ្រាំទ្រនឹងការរំលោភបំពានដែលពួកគេទទួលរង"*

អ្នកចូលរួមពិភាក្សាក្រុមត្រូវបានស្នើឱ្យពិពណ៌នាអំពី បទពិសោធន៍របស់ពួកគេក្នុងការទទួលបានការអប់រំ។ អ្នកចូលរួមភាគច្រើនបានទទួលរងនូវការរើសអើងមួយចំនួនពីមិត្តរួមថ្នាក់ និង/ឬគ្រូបង្រៀន ថ្វីបើអ្នកស្រឡាញ់ទាំងពីរភេទ និងស្ត្រីស្រលាញ់ភេទដូចគ្នាបានរាយការណ៍អំពីការរើសអើងតិចតួច ក៏ដោយសារពួកគេមានការងាយស្រួលក្នុងការលាក់អត្តសញ្ញាណរបស់ពួកគេ។ ទោះយ៉ាងណា អ្នកចូលរួមស្ត្រីស្រឡាញ់ភេទដូចគ្នាទាំង ៣នាក់បានយល់ស្របថា ប្រសិនបើមិត្តភក្តិរបស់ពួកគេដឹងថាពួកគេជាស្រីស្រលាញ់ស្រី មិត្តភក្តិនឹងឈប់និយាយជាមួយពួកគេ។ អ្នកចូលរួមដែលជាអ្នកស្រឡាញ់ទាំងពីរភេទមួយចំនួន ក៏បានរាយការណ៍ពីការភ័យខ្លាចដូចគ្នាផងដែរ ហើយម្នាក់ក្នុងចំណោមពួកគេបានសារភាពថា៖ "មានមនុស្សពីរបីនាក់បានឈប់និយាយជាមួយខ្ញុំនៅពេលពួកគេដឹងថាខ្ញុំជាមនុស្សស្រឡាញ់ទាំងពីរភេទ"

អ្នកចូលរួមបុរសស្រលាញ់ភេទដូចគ្នាទាំង៧នាក់បានទទួលការជេរប្រមាថនៅឯសាលារៀន ហើយត្រូវបានគេហៅពាក្យមិនល្អដូចជា " អា ខ្ទើយ" ឬ " អា ចេក" [45]។



" សម្រាប់អនាគតសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា ការអប់រំ គឺជាកត្តាសំខាន់ដែលជួយទាំងអ្នកស្រលាញ់ភេទដូចគ្នា ឲ្យស្ថិតនៅក្នុងប្រព័ន្ធអប់រំមួយ ដែលមានតម្លៃថ្លៃសម្រាប់ប្រជាជនភាគច្រើនដែលក្រីក្រ ហើយនិងធ្វើការផ្លាស់ប្តូរឥរិយាបថនៅក្នុងប្រព័ន្ធអប់រំ ដូច្នេះក្រុមអ្នកស្រឡាញ់ភេទដូចគ្នាមិនបោះបង់ចោលការសិក្សា នៅពេលពួកគេមិនអាចទ្រាំទ្រនឹងការរំលោភបំពានដែលពួកគេទទួលរង "

[45] Derogatory terms in Khmer often used to insult LGBTQI people.

ពួកគេប្រាំនាក់ក៏បានសារភាពថា បានបាត់បង់មិត្តភក្តិនៅពេលបានដឹងថាពួកគេជាអ្នកស្រឡាញ់ភេទដូចគ្នា ហើយពួកគេបួននាក់បានឈប់រៀនដោយសារតែគ្រូមិនអនុញ្ញាតឱ្យពួកគេបង្ហាញពីការស្រឡាញ់ភេទដូចគ្នា។

អ្នកចូលរួមដែលជាអ្នកប្តូរយេនឌ័រ បានរាយការណ៍អំពីបញ្ហាស្រដៀងគ្នានេះ។ អ្នកប្តូរយេនឌ័រជាបុរសទាំងបួននាក់បាននិយាយថា គ្រូរបស់ពួកគេនឹងមិនអនុញ្ញាតឱ្យពួកគេស្លៀកពាក់ដូចបុរសទេ ហើយតម្រូវឱ្យពួកគេស្លៀកពាក់ឯកសណ្ឋាននារី។ ពីរនាក់ក្នុងចំណោមពួកគេបានរាយការណ៍អំពីការរើសអើង និងការជេរប្រមាថពីមិត្តរួមថ្នាក់។ ពួកគេបាននិយាយថាសិស្សភាគច្រើននឹងបដិសេធមិនអង្គុយនៅជិតពួកគេដោយខ្លាចមានការឆ្លងតាម និងក្លាយជាអ្នកប្តូរយេនឌ័រដែរ។ អ្នកប្តូរយេនឌ័រជាស្ត្រីទាំងអស់ត្រូវបានរងការរើសអើងពីមិត្តរួមថ្នាក់ និងគ្រូរបស់ពួកគេ ហើយពួកគេ៣នាក់បានរាយការណ៍ថា ត្រូវបានវាយដំដោយសិស្សប្រុសៗ។

នៅពេលដែលអ្នកចូលរួមត្រូវបានសួរអំពីការអប់រំខ្ពស់បំផុតដែលអ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI) មានលទ្ធភាពទទួលបាន ចម្លើយបានផ្លាស់ប្តូរយោងទៅតាមអត្តសញ្ញាណ និងបទពិសោធន៍របស់អ្នកចូលរួម។ អ្នកស្រឡាញ់ទាំងពីរភេទ និងស្ត្រីស្រឡាញ់ភេទដូចគ្នា ហាក់ដូចជាអាចបញ្ចប់ថ្នាក់វិទ្យាល័យ ឬសូម្បីតែបរិញ្ញាបត្របាន ប្រសិនបើពួកគេមិនបានបើកចំហអំពីទំនោរផ្លូវភេទរបស់ពួកគេ។ អ្នកដែលចេញមុខ ជាធម្មតាបោះបង់ការសិក្សានៅវិទ្យាល័យ។ បុរសស្រឡាញ់ភេទដូចគ្នា ជាធម្មតាអាចបញ្ចប់វិទ្យាល័យ។ កម្រិតនៃការអប់រំរបស់អ្នកប្តូរយេនឌ័រ អាចខុសគ្នាអាស្រ័យលើពេលដែលពួកគេចាប់ផ្តើមធ្វើការផ្លាស់ប្តូរតាមយេនឌ័ររបស់ពួកគេ ប៉ុន្តែជាធម្មតាពួកគេបញ្ចប់ថ្នាក់បឋមសិក្សា។

នៅពេលត្រូវបានសួរថា តើមានទម្រង់ផ្សេងៗបែបណានៃការអប់រំ ដែលអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) អាចមានជាជម្រើសជំនួសការអប់រំផ្លូវការ អ្នកចូលរួមទាំងអស់បានលើកឡើងអំពីវគ្គសិក្សាបង្កើនជំនាញនៅក្នុងសាលាឯកជន ដូចជាវគ្គកុំព្យូទ័រ ឬភាសាបរទេសជាដើម សម្រាប់អ្នកដែលមានលទ្ធភាព។ អ្នកចូលរួមចំនួន ១៣នាក់បានលើកឡើងពីឱកាសបណ្តុះបណ្តាលនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង២៣នាក់បានលើកឡើងអំពីការងារ ឬការស្ម័គ្រចិត្តសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលជាមធ្យោបាយមួយក្នុងការទទួលបានចំណេះដឹង និងជំនាញ។

**បញ្ហាប្រឈម និងការលំបាកសំខាន់។**

អ្នកចូលរួមទាំងអស់បានរាយការណ៍ថាឆ្លងកាត់ឧបសគ្គ និងការលំបាកជាច្រើនក្នុងពេលដែលទៅទទួលការអប់រំជាផ្លូវការ រាប់ចាប់ពីភាពក្រីក្ររហូតដល់ការរើសអើងនៅសាលារៀន ឬក្នុងគ្រួសារ។ ក្នុងចំណោមអ្នកចូលរួមដែលជាអ្នកស្រឡាញ់ទាំងពីរភេទ ពីរនាក់បានឈប់រៀនហើយចាប់ផ្តើមធ្វើការព្រោះគ្រួសាររបស់ពួកគេក្រីក្រណាស់។ ពីរនាក់បានឈប់រៀនដោយសារការធ្លាក់ទឹកចិត្ត និងការ រើសអើងដោយគ្រួសារ និងសហគមន៍របស់ពួកគេ។ ហើយ ៣នាក់ទៀតរាយការណ៍ថា មានមិត្តភក្តិតិចនៅសាលា ដោយសារតែពួកគេជាអ្នកស្រឡាញ់ទាំងពីរភេទ។ អ្នកចូលរួមដែលជាបុរសស្រលាញ់ភេទដូចគ្នាទាំងអស់បានរាយការណ៍ថា ទទួលរងការ រើសអើងគ្រប់ប្រភេទ និង៥នាក់ត្រូវបានរាយការណ៍ថា មានអារម្មណ៍ឯកោនៅឯសាលារៀនដោយសារតែការមិនទទួលស្គាល់ការស្រឡាញ់ភេទដូចគ្នារបស់ពួកគេ។ អ្នកចូលរួមដែលជាស្ត្រីស្រឡាញ់ភេទដូចគ្នាទាំងអស់បាននិយាយថា ពួកគេមិនអាចមានលទ្ធភាពបង់ថ្លៃការសិក្សាបានទេ ហើយពួកគេទាំងអស់បានរាយការណ៍អំពីការរើសអើងពីក្រុមគ្រួសាររបស់ពួកគេ។ ម្នាក់ក្នុងចំណោមពួកគេបានរាយ ការណ៍ អំពីការប្រមាថមើលងាយ និងការសម្លុតពីគ្រូ និងសិស្ស។

អ្នកប្តូរយេនឌ័រជាបុរសទាំងអស់ បានរាយការណ៍ពីការរើសអើងដោយមិត្តរួមថ្នាក់របស់ពួកគេ និងអ្នកប្តូរយេនឌ័រជាស្ត្រីទាំងអស់បាននិយាយថា ពួកគេត្រូវបានបង្ខំឱ្យស្លៀកពាក់ឯកសណ្ឋានសិស្សប្រុសនៅសាលា។ ក្នុងចំនោមពួកគេ ៩នាក់ត្រូវឈប់រៀនព្រោះពួកគេមិនមានថវិកាគ្រប់គ្រាន់ ឬការផ្គត់ផ្គង់ហិរញ្ញវត្ថុពីក្រុមគ្រួសារ ហើយ៣នាក់បានបង្ហាញថាពួកគេទទួលរងការសម្លុតគំរាមពីគ្រូ និងមិត្តរួមថ្នាក់។ អ្នកប្តូរយេនឌ័រជាស្ត្រីអាយុ ២២ឆ្នាំម្នាក់បាននិយាយថា "មិត្តរួមថ្នាក់ខ្លះមិនចូលចិត្តអង្គុយក្បែរខ្ញុំទេ ពីព្រោះពួកគេខ្លាចក្លាយជាអ្នកប្តូរយេនឌ័រដែរនៅពេលប៉ះរាងកាយខ្ញុំ" ។

## សុខភាព

ដូចនៅក្នុងប្រទេសដទៃទៀតដែរ ការទទួលស្គាល់ដោយសមាជិកគ្រួសារ គឺប្រហែលជាឧបសគ្គធំបំផុតមួយដែលសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ប្រឈមមុខនៅក្នុងប្រទេសកម្ពុជា ហើយការបដិសេធរបស់ក្រុមគ្រួសារអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពផ្លូវចិត្តរបស់បុគ្គលដែលមិនបំពេញតាមការរំពឹងទុកនៃបទដ្ឋានស្រឡាញ់ភេទផ្ទុយគ្នា។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាថ្នាក់ជាតិឆ្នាំ ២០១៤ បានរាយការណ៍អំពីការកើតឡើងនៃការធ្លាក់ទឹកចិត្ត ការប៉ុនប៉ងធ្វើអត្តឃាត ការឱ្យតម្លៃលើខ្លួនឯងទាប និងបញ្ហាផ្លូវចិត្តដទៃទៀតក្នុងចំណោមយុវជនស្រឡាញ់ភេទដូចគ្នា។ ពួកគេក៏បានកត់សម្គាល់ផងដែរអំពីការខ្វះខាតទូទៅនៃសេវាកម្ម និងអ្នកអនុវត្តដែលមានលក្ខណៈរួសរាយ ជាពិសេសសម្រាប់ស្ត្រីស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រ ក៏ដូចជាកង្វះការប្រឹក្សាយោបល់ និងការថែទាំសុខភាពផ្លូវចិត្តគ្រប់គ្រាន់។ មនុស្សមួយចំនួនត្រូវបានបង្ខំឱ្យឆ្លងកាត់ការព្យាបាលជំងឺផ្លូវចិត្ត ឬការព្យាបាលឱ្យផ្លាស់ប្តូរពីការស្រឡាញ់ភេទដូចគ្នា ខណៈពេលដែលអ្នកផ្សេងទៀតត្រូវបានណែនាំដោយអ្នកប្រឹក្សាយោបល់ ឱ្យផ្លាស់ប្តូរអាកប្បកិរិយា របស់ពួកគេ។[46]

របាយការណ៍ឆ្នាំ ២០១៩ របស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា (RoCK) ស្តីពីអំពើហឹង្សាក្នុងគ្រួសារនៃស្ត្រីស្រឡាញ់ភេទដូចគ្នា(LBT)នៅក្នុងប្រទេសកម្ពុជា បានបង្ហាញថា ៨១ភាគរយនៃអ្នកចូលរួមក្នុងការសិក្សាបានទទួលរងនូវអំពើហឹង្សាផ្លូវចិត្តដោយសមាជិកគ្រួសារ។ ១១ភាគរយបានទទួលរងនូវអំពើហឹង្សាលើរាងកាយ និង១០ភាគរយបានទទួលរងនូវអំពើហឹង្សាផ្លូវភេទ រួមទាំងការរៀបការដោយបង្ខំ។ អាកប្បកិរិយាហឹង្សាបែបនេះបានបណ្តាលឱ្យមានបញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ ក្នុងចំណោមស្ត្រីស្រឡាញ់ភេទដូចគ្នា (LBT) ហើយជាច្រើននាក់បានរាយការណ៍ថាមានជំងឺធ្លាក់ទឹកចិត្ត។ ៣៥ភាគរយនៃអ្នកចូលរួមការសិក្សាបានគិត ឬប៉ុនប៉ងធ្វើអត្តឃាតដោយសារគ្រួសាររបស់ពួកគេបដិសេធនូវនិន្នាការភេទ ឬអត្តសញ្ញាណ និងការបង្ហាញយេនឌ័ររបស់ពួកគេ។[47]

វាជាការសំខាន់ក្នុងការកត់សម្គាល់ថា ក្រុមតូចៗនៅក្នុងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ត្រូវបានរងផលប៉ះពាល់មិនដូចគ្នា ដោយសារកង្វះសេវាសុខភាពគ្រប់គ្រាន់ ហើយអ្នកប្តូរយេនឌ័រ គឺប្រឈមនឹងហានិភ័យកាន់តែច្រើន។ ការវះកាត់ប្តូរភេទ និងនីតិវិធីពាក់ព័ន្ធដូចជាការប្រើប្រាស់ថ្នាំអរម៉ូន និងថ្នាំដទៃទៀតមិនមាននៅកម្ពុជាទេ ហើយអ្នកដែលមានធនធានហិរញ្ញវត្ថុ ច្រើនតែធ្វើដំណើរទៅប្រទេសថៃសម្រាប់ការផ្លាស់ប្តូរភេទរបស់ពួកគេ ដោយយោងតាមរបាយការណ៍ឆ្នាំ២០១៤ របស់អង្គការUNDP និងUSAID។របាយការណ៍នេះក៏បានបង្ហាញផងដែរថា អ្នកប្តូរយេនឌ័រជាស្ត្រីមួយចំនួនទទួលរងនូវផលវិបាកដ៏គ្រោះថ្នាក់ ឬអាចស្លាប់ដោយសារការប្រើប្រាស់ការចាក់ និងប្រេង ដែលមិនមានការត្រួតពិនិត្យ និងដឹងពីរបៀបប្រើប្រាស់ត្រឹមត្រូវ។

ការបង្ការមេរោគអេដស៍ ហាក់ដូចជាសេវាសុខាភិបាលតែមួយគត់ ដែលមានការដាក់បញ្ចូល នៅក្នុងប្រទេសកម្ពុជា។ អ្នកប្តូរយេនឌ័រ និងបុរសរួមភេទជាមួយបុរស គឺជាក្រុមគោលដៅនៃការសិក្សាអំពីមេរោគអេដស៍ និងគោលនយោបាយសាធារណៈ ចាប់តាំងពីឆ្នាំ២000 ហើយទាំងពីរត្រូវបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអេដស៍ថ្នាក់ជាតិ[48]។ ទោះបីជាបណ្តាញនៃប្រជាជទាំងនេះត្រូវបានបង្កើតមានឡើងតាំងពីឆ្នាំ២០០៦ក៏ដោយ ក៏ពួកគេនៅតែប្រឈមនឹងការមាក់ងាយ និងការរើសអើងពីអ្នកជំនាញផ្នែកសុខភាព ហើយនៅតែត្រូវបានចុះបញ្ជីក្នុងចំណោមក្រុមដែលមានហានិភ័យបំផុតក្នុងការរីករាលដាលមេរោគអេដស៍នៅក្នុងប្រទេស។[49] លើសពីនេះទៅទៀត ពួកគេត្រូវបានគេចាត់ទុកជាក្រុម

[46] UNDP, USAID (2014). Being LGBTI in Asia: Cambodia Country Report. Bangkok. At: https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf

[47] (RoCK (2019). Family Violence towards Lesbian, Bisexual and Transgender (LBT) People in Cambodia. At: http://www.suarakita.org/wp-content/uploads/2019/07/Family-Violence-towards-Lesbian-Bisexual-and-Transgender-LBT-People-in-Cambodia-Report.pdf

[48] National AIDS Authority, (NAA). (2010). National Strategic Plan for a Comprehensive and Multi-sectoral Response to AIDS for 2011-2015. p. 29..At: https://www.ilo.org/wcmsp5/groups/public/---ed_protect/---protrav/---ilo_aids/documents/legaldocument/wcms_177742.pdf

[49] Salas V & Srun S. (2013). An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities and their ways of coping.' Research report. Social Protection Coordination Unit, Council for

ដែលមានភាពចម្រុះនៅក្នុងវិស័យសុខភាពសាធារណៈ ទោះបីជាមានការខិតខំប្រឹងប្រែងថ្មីៗដើម្បីដោះស្រាយតម្រូវការជាក់លាក់របស់ពួកគេក៏ដោយ។ អង្គការ UNDP និងទីភ្នាក់ងារ USAID បានបញ្ជាក់ក្នុងឆ្នាំ ២០១៤៖

*“តម្រូវការបង្ការមេរោគអេដស៍នៃក្រុមគោលដៅចម្រុះផ្សេងៗគ្នា ត្រូវតែត្រូវបានដោះស្រាយឱ្យបានទូលំទូលាយជាងការធ្វើតេស្តរកមេរោគអេដស៍ និងការប្រើប្រាស់ស្រោមអនាម័យ។ នៅមានចន្លោះប្រហោងសំខាន់ៗនៅក្នុងការអាចរកបាន និងការទទួលបានសេវាសុខភាពផ្លូវភេទ និងបន្តពូជ ក៏ដូចជាសេវាសុខភាពទូទៅ និងសុខភាពបឋម។ ភាពខុសគ្នានៅក្នុងក្រុមរងនៃក្រុមបុរសរួមភេទជាមួយបុរស និងអ្នកប្តូរយេនឌ័រ ត្រូវការការទទួលស្គាល់ និងរាប់បញ្ចូលដូចជា អាយុការអប់រំ ការប្រព្រឹត្តផ្លូវភេទ និងក្រុមមិត្តភក្តិ”*[50]

នៅពេលអ្នកចូលរួមការពិភាក្សាក្រុមត្រូវបានសួរអំពីសេវាកម្មសុខភាពជាទូទៅដែលពួកគេទទួលបាន ចម្លើយទូទៅបំផុត គឺការព្យាបាលសុខភាពផ្លូវភេទ និងសុខភាពផ្លូវចិត្ត។ យោងទៅតាមក្រុមនៃអត្តសញ្ញាណនីមួយៗចម្លើយរបស់ពួកគេគឺ៖

- អ្នកស្រលាញ់ទាំងពីរភេទ៖ ការព្យាបាលមេរោគអេដស៍ និងការថែទាំសុខភាពទូទៅ។
- បុរសស្រឡាញ់ភេទដូចគ្នា៖ អ្នកចូលរួមទាំងអស់ បានទទួលការធ្វើតេស្តរកមេរោគអេដស៍ ការព្យាបាលជំងឺកាមរោគ និងការថែទាំសុខភាពបឋម។ បីនាក់បានទទួលការវះកាត់កែសម្ផស្ស ហើយម្នាក់ទៀតបានទទួលការព្យាបាលការប្រើគ្រឿងញៀន។
- អ្នកប្តូរយេនឌ័រជាបុរស៖ អ្នកចូលរួមទទួលបានសេវាសុខភាព ដើម្បីព្យាបាលការឈឺដៃ ឈឺជើង បញ្ហាក្រពះ និងពោះវៀន។
- អ្នកប្តូរយេនឌ័រជាស្ត្រី៖ ពួកគេទាំងអស់ទទួលបានការព្យាបាលមេរោគអេដស៍ និងកាមរោគ ការព្យាបាលសុខភាពទូទៅ និងសុខភាពផ្លូវចិត្ត។ ដប់នាក់បានធ្វើការវះកាត់កែសម្ផស្ស និងការចាក់អរម៉ូន។
- ស្ត្រីស្រលាញ់ភេទដូចគ្នា៖ ពួកគេទាំងអស់បានទទួលការធ្វើតេស្តឈាម ការព្យាបាលសុខភាពផ្លូវចិត្ត និងការថែរក្សាសុខភាពផ្លូវភេទរបស់ស្ត្រី។

## មណ្ឌលសុខភាព

អ្នកចូលរួមត្រូវបានសួរ អំពីកន្លែងដែលពួកគេទទួលបានសេវាសុខភាពទាំងនេះជាធម្មតា៖

- អ្នកស្រលាញ់ទាំងពីរភេទ៖ គ្លីនិចឈូក[51] និងអង្គការសុខភាពបុរសនៅកម្ពុជា(MHC)[52]
- បុរសស្រលាញ់ភេទដូចគ្នា៖ មណ្ឌលសុខភាព គ្លីនិចឈូកស គ្លីនិកឯកជន មន្ទីរពេទ្យរដ្ឋ
- អ្នកប្តូរយេនឌ័រជាបុរស៖ គ្លីនិកឯកជន
- អ្នកប្តូរយេនឌ័រជាស្ត្រី៖ អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់) និងគ្លីនិកឯកជន
- ស្ត្រីស្រលាញ់ភេទដូចគ្នា៖ មន្ទីរពេទ្យរដ្ឋ និងគ្លីនិកឯកជន។

## បញ្ហាប្រឈម

នៅពេលត្រូវបានសួរ អំពីបញ្ហាប្រឈមក្នុងការទទួលបានសេវាសុខភាព ភាពក្រីក្រ និងការរើសអើង គឺជាប្រធានបទញឹកញាប់នៅក្នុងចម្លើយរបស់អ្នកចូលរួម។

អ្នកចូលរួមដែលជាអ្នកស្រឡាញ់ទាំងពីរភេទបាននិយាយថា ពួកគេមិនមានអារម្មណ៍ងាយស្រួលក្នុងការបង្ហាញពីទំនោរភេទរបស់ពួកគេទៅកាន់គ្រូពេទ្យទេ។

---

Agricultural Research and Development (SPCU-CARD), Phnom Penh.

[50] UNDP, USAID (2014). Being LGBTI in Asia: Cambodia Country Report, p. 49. Bangkok. At: https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf

[51] Chouk Sor is a clinic which provides services on testing and treatment on HIV/AIDS: https://www.facebook.com/pages/category/Medical-Research-Center/Chhouk-Sar-Clinic-131924400738356/

[52] Men Health's Cambodia (MHC) is a local non-profit non-governmental organisation working on HIV-AIDS prevention intervention for men who have sex with men and transgender women across Cambodia. MHC aims to promote HIV prevention messages, HIV testing and PrEP. At: https://www.facebook.com/MensHealthCambodia

ពីរនាក់ក្នុងចំណោមពួកគេមានការភ័យខ្លាចជាពិសេសថា គ្រូពេទ្យនឹងមិនរក្សាការសម្ងាត់របស់អ្នកជំងឺ ហើយបួននាក់ទៀតធ្លាប់ត្រូវបានគ្រូពេទ្យរើសអើងរួចហើយ។ បុរស និងស្ត្រីស្រលាញ់ភេទដូចគ្នាទាំងអស់ ក៏បានរាយការណ៍ពីការភ័យខ្លាចក្នុងការបង្ហាញពីទំនោរភេទរបស់ពួកគេដល់អ្នកជំនាញផ្នែកសុខភាព ក៏ដូចជាកង្វះខាតធនធានហិរញ្ញវត្ថុ សម្រាប់ការព្យាបាលរបស់ពួកគេ។ ស្ត្រីស្រឡាញ់ភេទដូចគ្នាអាយុ២១ឆ្នាំម្នាក់ បាននិយាយថា "ខ្ញុំខ្លាចការរើសអើង ប្រសិនបើខ្ញុំប្រាប់គ្រូពេទ្យថាខ្ញុំជាស្រីស្រលាញ់ស្រី"។ បុរសស្រឡាញ់ភេទដូចគ្នាបួននាក់ ក៏បានរាយការណ៍ពីការលំបាកក្នុងការធ្វើដំណើរផងដែរព្រោះមន្ទីរពេទ្យនៅឆ្ងាយពីផ្ទះ ហើយ៣នាក់ជឿថាគ្រូពេទ្យមិនមានសមត្ថភាពគ្រប់គ្រាន់។

អ្នកប្តូរយេនឌ័រទាំងអស់បានរាយការណ៍ថាពួកគេមិនអាចមានលទ្ធភាពបង់ថ្លៃថែទាំសុខភាពរបស់ពួកគេទេ។ អ្នកប្តូរយេនឌ័រជាស្ត្រីចំនួន៧នាក់ បានត្អូញត្អែរអំពីការព្យាបាលដែលពួកគេទទួលបានពីគ្រូពេទ្យ និងបុគ្គលិកទទួលភ្ញៀវ ហើយ៧នាក់ទៀតត្រូវបានអ្នក ជំនាញផ្នែកសុខភាពនិយាយប្រមាថមើលងាយ។ អ្នកប្តូរយេនឌ័រជាស្ត្រីប្រឈមនឹងគ្រោះថ្នាក់សុខភាព ព្រោះនីតិវិធីវះកាត់ប្តូរយេនឌ័រ (gender reassignment procedures) មិនមានលក្ខណៈស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ អ្នកដែលមិនអាចមានលទ្ធភាពធ្វើដំណើរទៅប្រទេសថៃ និងបង់ប្រាក់សម្រាប់ការវះកាត់របស់ពួកគេ ច្រើនតែប្រើការចាក់អរម៉ូនដែលខុសច្បាប់ និងគ្មានសុវត្ថិភាព។ អ្នកប្តូរយេនឌ័រជាស្ត្រីអាយុ២៥ឆ្នាំម្នាក់ បានសារភាពថា

*"ខ្ញុំបានចាក់ថ្នាំអរម៉ូនមិនមានហាងត្រឹមត្រូវ ដែលខ្ញុំទទួលបានពីមិត្តភក្តិរបស់ខ្ញុំ ហើយឥឡូវនេះខ្ញុំមានដើមទ្រូងអាក្រក់"។*

# ៦. សេចក្តីសន្និដ្ឋាន

ដូចដែលលទ្ធផលនៃការពិភាក្សាក្រុមបង្ហាញភស្តុតាងដែលប្រមូលបានតាមរយៈចម្លើយរបស់អ្នកចូលរួមទាំង ៣២នាក់ គឺទាក់ទងទៅនឹងការស្រាវជ្រាវពីមុន និងបច្ចុប្បន្ន ព្រមទាំងសង្កត់ធ្ងន់ទៅលើលំនាំនៃការរើសអើង ដែលមានបទពិសោធន៍ដោយអ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI) នៅកម្ពុជា។ ស្រដៀងនឹងការរកឃើញនៃការសិក្សា ការស្ទង់មតិ ការប្រមូលទិន្នន័យ និងរបាយការណ៍ផ្សេងទៀត អ្នកចូលរួមការពិភាក្សាក្រុម (FGD) បានរាយការណ៍អំពីការរងនូវការរើសអើងជាបន្តបន្ទាប់៖

- ពីគ្រួសារ និងសហគមន៍របស់ពួកគេ
- នៅសាលា
- នៅកន្លែងធ្វើការ
- នៅតាមមណ្ឌលថែទាំសុខភាព
- ដោយស្ថាប័នហិរញ្ញវត្ថុ។

ការរើសអើងគ្រប់ស្រទាប់ទាំងអស់នេះ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមិនត្រឹមតែចំពោះសុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះសមិទ្ធិផលនៃការសិក្សាអប់រំ និងជំនាញវិជ្ជាជីវៈរបស់ពួកគេផងដែរ ដូច្នេះវាអាចបង្កហានិភ័យដល់ឱកាសនៃការធ្វើឱ្យមានភាពប្រសើរឡើងនូវជីវភាពរស់នៅ ការចាកចេញពីភាពក្រីក្រ និងឈានទៅដល់សក្តានុពលពេញលេញរបស់ពួកគេ។

វាជាការពាក់ព័ន្ធក្នុងការលើកឡើងថា ការងារប្រកបរបររកស៊ីផ្លូវភេទជាប្រធានបទដែលមិនបានឡើងនៅក្នុងការពិភាក្សាក្រុម (FGD) ទោះបីជាត្រូវបានឃើញការលើកឡើងនៅក្នុងការសរសេរមុនៗ និងបច្ចុប្បន្នថាគឺជាសកម្មភាពរួមមួយមាននៅក្នុងចំណោមសហគមន៍អ្នកប្តូរយេនឌ័រ។ នេះដោយសារតែការងារប្រកបរបររកស៊ីផ្លូវភេទ គឺខុសច្បាប់នៅក្នុងប្រទេស ហើយអ្នកចូលរួមមិនចាត់ទុកវាជាការងារ ឬមុខរបរជាក់ស្តែងនោះទេ ទោះបីភាគច្រើនជាអ្នកធ្លាប់ ឬកំពុងប្រកបរបររកស៊ីផ្លូវភេទក៏ដោយ។

ខាងក្រោមនេះ គឺជាការវិភាគនៃខ្លឹមសាររួមដែលលេចចេញពីការពិភាក្សាក្រុម (FGDs) និងបានលើកឡើងក្នុងចំណោមអ្នកចូលរួមទាំងអស់។ ការត្រួតពិនិត្យមួយក៏ត្រូវបានធ្វើឡើងអំពីបញ្ហាដែលជះឥទ្ធិពលលើពួកគេខុសៗគ្នា ដោយពិចារណាលើលក្ខណៈរសើបពិសេស និងឯកសិទ្ធិដែលក្រុមមានអត្តសញ្ញាណជាក់លាក់នីមួយៗមានលើសពីអ្នកដទៃ។

## ប្រធានបទទូទៅ

ការពិភាក្សាក្រុមផ្តោតសំខាន់ត្រូវបានធ្វើឡើងតាមរបៀបមួយ ដែលអនុញ្ញាតឱ្យមានការបែងចែកចម្លើយដោយយោងទៅតាមអត្តសញ្ញាណអ្នកស្រឡាញ់ភេទដូចគ្នានីមួយៗ។ ទោះយ៉ាងណាក៏ដោយ វាជាភស្តុតាងជាក់ស្តែងនៅក្នុងការបញ្ជាក់មូលហេតុរបស់អ្នកចូលរួមដែលពួកគេចែករំលែកនូវបញ្ហាប្រឈម និងឧបសគ្គទូទៅដោយមិនគិតពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ឬការបង្ហាញយេនឌ័ររបស់ពួកគេ។

នៅពេលនិយាយអំពីការងារ អ្នកចូលរួមបានរាយការណ៍ ជាឯកច្ឆន្ទថាអត្តសញ្ញាណអ្នកស្រឡាញ់ភេទដូចគ្នារបស់ពួកគេ ជាធម្មតាបញ្ឈប់ពួកគេពីការស្វែងរក ឬរក្សាការងារ។ និយោជក និងអ្នករួមការងារហាក់ដូចជាមិនគោរពទំនោរផ្លូវភេទ អត្តសញ្ញាណ ឬការបង្ហាញយេនឌ័ររបស់ពួកគេ ហើយពួកគេច្រើនតែរងគ្រោះដោយសារការជេរប្រមាថមើលងាយ ការបៀតបៀនរំខាន និងការរំលោភបំពាននៅកន្លែងធ្វើការ។ លើសពីនេះទៅទៀតអ្នកចូលរួមជាច្រើនបាននិយាយថា ការឈប់ពីការសិក្សាលឿនរបស់ពួកគេ បានបញ្ឈប់ពួកគេពីការទទួលបានចំណេះដឹង និងជំនាញចាំបាច់ដើម្បីទទួលបានការងារល្អប្រសើរ។ អ្នកចូលរួមទាំងអស់បានបង្ហាញពីបំណងចង់បើកអាជីវកម្មខ្នាតតូចផ្ទាល់ខ្លួន ដែលជាមធ្យោបាយមួយផ្សេងទៀតក្នុងការរកប្រាក់ចំណូល ប៉ុន្តែពួកគេកម្រមានធនធានហិរញ្ញវត្ថុដើម្បីធ្វើបែបហ្នឹងណាស់។

ភាពលំបាកផ្នែកហិរញ្ញវត្ថុ គឺជាតថភាពទូទៅសម្រាប់អ្នកចូលរួមទាំងអស់ ដោយសារតែភាពក្រីក្រ និងការរើសអើង។ អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ស្ថិតជាប់នៅក្នុងវដ្តនៃភាពក្រីក្រ ដោយសារតែការរើសអើងពីគ្រួសារ នៅក្នុងសាលារៀន និងនៅកន្លែងធ្វើការរបស់ពួកគេដូច្នេះហើយមិនអាចបំពេញការចំណាយក្នុងការរស់នៅរបស់ពួកគេបានទេ។ លើសពីនេះទៀតអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) មិនអាចទទួលបានសេវាកម្មធនាគារទេ ពីព្រោះពួកគេមិនមានឯកសារចាំបាច់គ្រប់គ្រាន់ ដោយសារតែការបដិសេធរបស់គ្រួសារ ហើយក្នុងករណីខ្លះដោយសារតែគ្រួសាររក្សាទុកឯកសារអត្តសញ្ញាណរបស់ពួកគេ។

ទាក់ទងនឹងការទទួលបានការអប់រំ អ្នកចូលរួមទាំងអស់បានទទួលរងនូវការសម្លុតមាក់ងាយគំរាមកំហែង និងការរើសអើងនៅក្នុងពេលខ្លះនៅឯសាលារៀនពីសំណាក់គ្រូ ឬសិស្ស ឬទាំងពីរ ដោយលើកឡើងថាសាលារៀននៅប្រទេសកម្ពុជាមិនផ្តល់កន្លែងទំនេរ និងមានសុវត្ថិភាពសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាទេ។ បរិយាកាសអរិភាពជាញឹកញាប់នេះ បានបង្ខំមនុស្សឱ្យបោះបង់ការសិក្សារបស់ពួកគេដែលបណ្តាលឱ្យមានជីវភាពក្រីក្រ និងការលំបាកផ្នែកហិរញ្ញវត្ថុ។ ក្នុងករណីខ្លះការបដិសេធរបស់ក្រុមគ្រួសារ ក៏នាំឱ្យខ្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលជាលទ្ធផលបានធ្វើឱ្យអន្តរាយដល់ឱកាសយុវជនស្រឡាញ់ភេទដូចគ្នា (LGBTQI) ក្នុងការទទួលបានការអប់រំកម្រិតខ្ពស់ផងដែរ។

បទពិសោធន៍របស់អ្នកចូលរួម នៅក្នុងមូលដ្ឋានសុខាភិបាលក៏មានបញ្ហា និងប្រឈមផងដែរ។ អ្នកចូលរួមទាំងអស់ ហាក់ដូចជាចែករំលែកអារម្មណ៍នៃការមិនទុកចិត្តដល់អ្នកជំនាញសុខភាពសាធារណៈ ពីព្រោះពួកគេច្រើនតែមិនមានសមត្ថភាពគ្រប់គ្រាន់ ឬមិនមានសមត្ថភាពសោះ ឬមិនទទួលបានការបណ្តុះបណ្តាល ដើម្បីផ្តល់ការព្យាបាលជាក់លាក់ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។ ដោយសារតែកម្រិតនៃភាពក្រីក្រ គឺជាការមិនទំនងដែលថាអ្នកស្រលាញ់ភេទដូចគ្នា អាចមានលទ្ធភាពថែទាំសុខភាពពីសេវាឯកជនបានទេ។

## លំនាំ និងកម្រិតនៃការរើសអើង មានភាពខុសគ្នាអាស្រ័យលើនិន្នាការភេទ អត្តសញ្ញាណនិងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ

ទោះបីជាអ្នកចូលរួមនៃការពិភាក្សាក្រុមជួបបទពិសោធន៍ស្រដៀងគ្នាក៏ដោយ វាជាការសំខាន់ដើម្បីគូសបញ្ជាក់ពីបញ្ហា និងស្ថានភាពមួយចំនួនដែលជះ

ឥទ្ធិពលជាពិសេសទៅលើក្រុមទៅតាមអត្តសញ្ញាណជាក់លាក់នីមួយៗ។

ស្ត្រីស្រលាញ់ភេទដូចគ្នា និងអ្នកស្រឡាញ់ទាំងពីរភេទ គឺទទួលការរើសអើងតិចតួចនៅសាលារៀន និងនៅកន្លែងធ្វើការប្រសិនបើពួកគេអាចលាក់បាំងទំនោរភេទរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើពួកគេចេញមុខ ឬត្រូវបានគេយល់ថាជាស្រីស្រលាញ់ស្រីដូចគ្នា គឺទំនងជាពួកគេនឹងទទួលរងនូវបទពិសោធន៍នៃការរើសអើងដូចក្រុមដទៃទៀតដែរ។ ដូច្នេះវាមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេ ដែលថាអ្នកចូលរួមដែលជាស្ត្រីស្រលាញ់ភេទដូចគ្នា និងអ្នកស្រឡាញ់ទាំងពីរភេទអាចទទួលបានការអប់រំជាផ្លូវការកម្រិតខ្ពស់។

ម្យ៉ាងវិញទៀតអ្នកប្តូរយេនឌ័រ គឺភាគច្រើនទំនងជាបានបញ្ចប់ការអប់រំតែនៅត្រឹមកម្រិតបឋមសិក្សា ដោយសារតែការផ្លាស់ប្តូរយេនឌ័ររបស់ពួកគេដែលធ្វើឱ្យពួកគេងាយរងគ្រោះពីការរើសអើង និងបង្ខំឱ្យពួកគេឆាប់បោះបង់ការសិក្សា។ ភាពមើលឃើញ និងរូបរាងកាយរបស់ពួកគេក៏រារាំងពួកគេពីការស្វែងរកឱកាសការងារ និង/ឬទុកឱ្យពួកគេទទួលរងនូវការបៀតបៀន និងការរំលោភបំពាននៅកន្លែងធ្វើការបន្ថែមទៀត។

វាជាការពាក់ព័ន្ធក្នុងការកត់សម្គាល់ថា បុរសស្រលាញ់ភេទដូចគ្នាអាចជួបប្រទះនូវបញ្ហាប្រឈមស្រដៀងគ្នានេះផងដែរ ដោយអាស្រ័យលើការមើលឃើញពីទំនោរផ្លូវភេទ ឬការបង្ហាញយេនឌ័ររបស់ពួកគេ ព្រោះថាការបង្ហាញយេនឌ័រជារឿយៗកំណត់ថា តើនៅកម្ពុជាអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ទទួលការឆ្លើយតប ឬស្វាគមន៍បែបណា។

ទាក់ទងនឹងសេវាសុខភាព ចម្លើយរបស់អ្នកចូលរួមបង្ហាញថាអ្នកប្តូរយេនឌ័រជាស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ និងបុរសស្រឡាញ់ភេទដូចគ្នា ទទួលបានការធ្វើតេស្តរកមេរោគអេដស៍ និងកាមរោគច្រើនជាងអ្នកប្តូរយេនឌ័រជាបុរស និងស្ត្រីស្រឡាញ់ភេទដូចគ្នាទទួលបាន។ នេះអាចបណ្តាលមកពីអ្នកប្តូរយេនឌ័រជាស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ និងបុរសស្រឡាញ់ភេទដូចគ្នាមានដៃគូរួមភេទច្រើន ដូច្នេះហើយមានហានិភ័យនៃការឆ្លងខ្ពស់។ អ្នកប្តូរយេនឌ័រជាស្ត្រីហាក់ដូចជាប្រឈមមុខនឹងការរើសអើងខ្ពស់ពីអ្នកផ្តល់សេវាសុខភាព ដោយសារតែរូបរាងកាយរបស់ពួកគេ និងទំនងជាមានហានិភ័យផ្នែកសុខភាពដោយសារតែការចាក់បញ្ចូលអរម៉ូន និងការវះកាត់មិនមានសុវត្ថិភាព។

បើនិយាយពីភាពលំបាកផ្នែកហិរញ្ញវត្ថុវិញ គេមិនអាចកំណត់នូវបញ្ហាប្រឈមខុសគ្នាក្នុងចំណោមក្រុមអត្តសញ្ញាណនីមួយៗបានទេ លើកលែងតែអ្នកប្តូរយេនឌ័រដែលអាចងាយរងគ្រោះទៅក្នុងភាពក្រីក្រ ដោយសារភាពញឹកញាប់នៃការរើសអើង។



# ៧. អនុសាសន៍

អនុសាសន៍ខាងក្រោមដែលផ្តោតជាចម្បងចំពោះរដ្ឋាភិបាល និងវិស័យឯកជន ភាគច្រើនពឹងផ្អែកលើបទពិសោធន៍ និងការផ្តល់យោបល់ដែលមានស្រាប់ដើម្បីធ្វើឱ្យប្រសើរឡើង ចេញពីអ្នកចូលរួមការពិភាក្សាក្រុមទាំង៣២នាក់។ អនុសាសន៍ខ្លះត្រូវបានក្រុមស្រាវជ្រាវធ្វើសេចក្តីព្រាងដោយផ្អែកលើការរកឃើញដែលមានស្រាប់ និងការរកឃើញថ្មីៗ។

APCOM និង MRIF រួមជាមួយដៃគូនានានឹងបន្តធ្វើការតស៊ូមតិ ដើម្បីទទួលបានការអនុវត្តនូវអនុសាសន៍ទាំងនេះ ក្នុងគោលបំណងដើម្បីលុបចោលនូវរចនាសម្ព័ន្ធ និងឧបសគ្គផ្សេងទៀត សម្រាប់ការដាក់បញ្ចូលផ្នែកសេដ្ឋកិច្ច ផ្នែកសង្គម និងការចូលរួមយ៉ាងពេញលេញសម្រាប់ប្រជាពលរដ្ឋអ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI) នៅក្នុងសង្គមកម្ពុជា។

**ការអនុម័តគោលនយោបាយមិនមានការរើសអើង និងការដាក់បញ្ចូល** ( **បរិយាបន** )

១. រដ្ឋាភិបាលគួរតែអនុវត្តនូវអនុសាសន៍ចំនួន ៩ ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណ ឬការបង្ហាញយេនឌ័រ នៅក្នុងការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់ជុំទី៣ (UPR-Third Cycle) ក្នុងឆ្នាំ២០១៩ របស់អង្គការសហប្រជាជាតិ។ នេះរួមបញ្ចូលទាំងការដាក់ចេញនូវច្បាប់ប្រឆាំងនឹងការរើសអើង ដែលធានានូវភាពស្មើគ្នា និងហាមឃាត់ដាក់លាក់ចំពោះការរើសអើងគ្រប់ប្រភេទ រាប់បញ្ចូលទាំងមូលដ្ឋានសាសនា និន្នាការភេទ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ ឬលក្ខណៈផ្លូវភេទ។ ហើយក៏រួមបញ្ចូលទាំងការអនុម័តនូវវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីប្រឆាំងនូវរាល់ការរើសអើង និងអំពើហឹង្សាចំពោះប្រជាពលរដ្ឋដោយសារតែនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ និងនាំខ្លួនជនល្មើសដើម្បីភាពយុត្តិធម៌។

២. រដ្ឋាភិបាលគួរតែអនុម័តច្បាប់អត្រានុកូលដ្ឋានថ្មី ដែលផ្តល់ការចុះបញ្ជីកំណើត អាពាហ៍ពិពាហ៍ និងមរណភាព រួមទាំងអនុវត្តផែនការសកម្មភាពឆ្លើយតបទៅនឹងតម្រូវការអាទិភាពសម្រាប់ប្រជាពលរដ្ឋអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ។

៣. សាលារៀន មណ្ឌលសុខភាព ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជីវកម្មឯកជនគួរតែបង្កើត និងអនុវត្តគោលនយោបាយមិនមានការរើសអើង និងធានាថាការអនុវត្តមានលក្ខណៈឆ្លើយតបចំពោះអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ។

៤. ពហុភាគីនៃធនាគារអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុគួរតែពង្រឹងការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ដោយការអភិវឌ្ឍ ការធ្វើសមាហរណកម្ម និងការអនុវត្តគោលនយោបាយផ្តោតលើកន្លែងធ្វើការ ផ្នែកហិរញ្ញវត្ថុ គោលនយោបាយផ្នែកសុខភាព និងការអប់រំរួមទាំងការអនុវត្ត។ ពួកគេគួរតែពង្រឹងសម្ព័ន្ធភាពប្រកបដោយប្រសិទ្ធភាពជាមួយស្ថាប័នរដ្ឋ និងតួអង្គមិនមែនរដ្ឋាភិបាលសម្រាប់កិច្ចសហប្រតិបត្តិការពហុភាគីដើម្បីលើកកម្ពស់ការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា។

៥. សិស្សនិស្សិតដែលជាអ្នកប្តូរយេនឌ័រ គួរតែមានលទ្ធភាពអាចស្លៀកពាក់ឯកសណ្ឋានសាលារៀនស្របតាមអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ ការអនុវត្តកម្មវិធីមិនមានការរើសអើង និងការដាក់បញ្ចូល (បរិយាបន)

៦. ស្ថាប័នហិរញ្ញវត្ថុ និងធនាគារខ្នាតតូច គួរផ្តល់ប្រាក់កម្ចីដោយមានលក្ខខណ្ឌអាចបត់បែនបានចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ដែលមានបំណងចាប់ផ្តើមអាជីវកម្មខ្នាតតូច។

៧.ធនាគារគួរតែផ្តល់ជូនសេវាកម្មដែលមានលក្ខណៈមេត្រីភាព ជាមួយនឹងលក្ខខណ្ឌដែលអាចបត់បែនបានសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ដែលរស់នៅក្នុងភាពក្រីក្រ។

៨. រដ្ឋាភិបាលគួរតែបង្កើតជាបន្ទាន់ ជាមួយនឹងថវិកាគ្រប់គ្រាន់ មានប្រសិទ្ធិភាព អនាមិក និងយន្តការដែលអាចចូលដំណើរការបានងាយស្រួលសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកដទៃទៀតដើម្បីធ្វើការរាយការណ៍អំពីអំពើហឹង្សា និងការរើសអើង។

៩. រដ្ឋាភិបាលគួរតែផ្តល់មូលនិធិដល់កម្មវិធីសម្រាប់បង្កើតក្រុមគាំទ្រដល់យុវជនអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀន និងសហគមន៍ ព្រមទាំងជំរុញបណ្តាញឪពុកម្តាយ អាណាព្យាបាល និងក្រុមគ្រួសាររបស់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ឲ្យចូលរួមជាកម្លាំងចលករ ព្រមទាំងធ្វើការតស៊ូមតិដើម្បីសិទ្ធិ និងឱកាសសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។

១០. ស្ថាប័នវិស័យអប់រំគួរតែបញ្ចូលប្រធានបទទាក់ទងនឹងការអប់រំផ្លូវភេទ និងយេនឌ័រនៅក្នុងកម្មវិធីសិក្សា រួមទាំងសិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។

១១. ប្រព័ន្ធសុខភាពសាធារណៈគួរតែមានសេវាកម្មតម្រង់ទិស និងអ្នកជំនាញដែលទទួលការបណ្តុះបណ្តាលអំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នាឱ្យបានគ្រប់គ្រាន់។

១២. រដ្ឋាភិបាលគួរតែផ្តល់ប័ណ្ណសមធម៌[53] ដែត្រូវបានស្គាល់ថាជាប័ណ្ណក្រីក្រ និងប័ណ្ណសម្រាប់ជនក្រីក្រ[54] ដល់អ្នកស្រឡាញ់ភេទដូចគ្នាដែលមានតម្រូវការ។ និងមណ្ឌលសុខភាពសាធារណៈគួរតែផ្តល់សេវា និងការព្យាបាលដោយឥតគិតថ្លៃទៅដល់អ្នកស្រលាញ់ភេទដូចគ្នាទាំងនោះ រួមទាំងមានការព្យាបាលអរម៉ូនដល់អ្នកប្តូរយេនឌ័រ។

## ការលើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាល

១៣. គ្រូបង្រៀន អ្នកផ្តល់សេវាផ្នែកសុខាភិបាល អាជ្ញាធរមូលដ្ឋាន និយោជក និងអ្នកផ្តល់សេវាហិរញ្ញវត្ថុ គួរតែទទួលបានការបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ពួកគេ និងអាចផ្តល់ជូនសេវាកម្មដែលមានមេត្រីភា និងជាក់លាក់សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា។ ទាំងនេះរួមបញ្ចូលទាំងការបណ្តុះបណ្តាលគ្រូអំពីរបៀបដើម្បីគាំទ្រសិស្សនិស្សិតដែលមិនមែនជាអ្នកស្រឡាញ់ភេទផ្ទុយគ្នា និងផ្តល់ការណែនាំដល់និយោជកវិស័យឯកជន អំពីរបៀបគោរព ការពារ និងលើកកម្ពស់សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកន្លែងធ្វើការ។

១៤. រដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត គួរតែធ្វើជាដៃគូជាមួយអង្គការ អ្នកស្រឡាញ់ភេទដូចគ្នា សម្រាប់ការដាក់បញ្ចូលនិន្នាការភេទ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (SOGIESC) និងភាពចម្រុះ និងដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា។ ការភ្ជាប់គម្លាតទិន្នន័យស្តីពីការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI)

១៥. ភាពជាដៃគូគួរតែត្រូវបានជំរុញរវាងវិស័យឯកជន និងស្ថាប័នសាធារណៈ ស្ថាប័នគ្រឹះស្ថានសិក្សា និងអង្គការសង្គមស៊ីវិលដែលធ្វើការលើសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) ហើយនិងមានមូលនិធិដែលអាចរកបានសម្រាប់ការស្រាវជ្រាវយ៉ាងម៉ត់ចត់បន្ថែមទៀត ដើម្បីកែលម្អ និងពង្រីកទិន្នន័យរួមទាំងព័ត៌មានដែលមានលើការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា។ ទាំងនេះនឹងជាការជូនដំណឹងដល់កម្មវិធីនានាដែលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយ និងកែលម្អស្ថានភាពរបស់ប្រជាពលរដ្ឋអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) នៅក្នុងថ្នាក់តំបន់។

១៦. សមត្ថភាពនៃការស្រាវជ្រាវរបស់អង្គការអ្នកស្រឡាញ់ភេទដូចគ្នា គួរតែត្រូវបានកសាង និងពង្រឹង ដើម្បីឱ្យពួកគេអាចរៀបចំបង្កើត អនុវត្តន៍ វាយតម្លៃ និងចូលរួមក្នុងគម្រោងស្រាវជ្រាវប្រកបដោយគុណភាព និងបរិមាណលើបញ្ហាដែលទាក់ទងនឹងអ្នកស្រឡាញ់ភេទដូចគ្នា។

## បង្កើតភាពជាដៃគូ

១៧. អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសកម្ពុជាដែលធ្វើការឆ្ពោះទៅរកការដាក់បញ្ចូលក្រុមអ្នកស្រឡាញ់ភេទដូចគ្នា រួមទាំងប្រជាពលរដ្ឋអ្នកស្រឡាញ់ភេទដូចគ្នាខ្លួនឯង សហគមន៍ អង្គការក្រៅរដ្ឋាភិបាល រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជន បណ្ឌិតសភា និងប្រព័ន្ធផ្សព្វផ្សាយគួរតែធ្វើការរួមគ្នា ព្រមទាំងស្វែងរក និងកំណត់ដំណោះស្រាយឱ្យបានទូលំទូលាយដើម្បីបំពេញ និងមានអត្ថន័យចំពោះការដាក់បញ្ចូលផ្នែកសេដ្ឋកិច្ច និងសង្គមសម្រាប់ប្រជាពលរដ្ឋអ្នកស្រឡាញ់ភេទដូចគ្នា ៕

[54] Equity Cards - also known as poverty cards and cards for the poor - is a government poverty identification programme which gives vulnerable people access to free health care and social support.

# ៨. ឯកសារយោង

Badgett, Lee, et al. (2014). The Relationship Between LGBT Inclusion and Economic Development: An Analysis of Emerging Economies. The Williams Institute, Los Angeles, USA.At: https://williamsinstitute.law.ucla.edu/publications/lgbt-inclusion-economic-dev/

Cambodia: Constitution of the Kingdom of Cambodia. At: https://www.wipo.int/edocs/lexdocs/laws/en/kh/kh009en.pdf

Cambodia: Law of 1989 on the Marriage and Family. (1989). At: rhttps://www.refworld.org/docid/3ae6b55c0.html

Cambodia: Law on Suppression of Human Trafficking and Sexual Exploitation.2008. At: https://www.unodc.org/res/cld/document/khm/2008/law_on_suppression_of_human_trafficking_and_sexual_exploitation_html/Cambodia_03_-_Law-on-Suppression-of-Human-Trafficking-and-Sexual-Exploitation-15022008-Eng.pdf

Cambodia Center for Human Rights (CCHR). (2010). Coming Out in the Kingdom: Lesbian, Gay, Bisexual and Transgender People in Cambodia. At: https://cchrcambodia.org/admin/media/report/report/english/2010-12-09%20COMING%20OUT%20IN%20THE%20KINGDOM%20LESBIAN,%20GAY,%20BISEXUAL%20AND%20TRANSGENDER%20PEOPLE%20IN%20CAMBODIA_EN%20.pdf

Cambodia Center for Human Rights (CCHR). (2012). Rainbow Khmer: From Prejudice to Pride. At: https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=85&id=3

Cambodian Alliance for Combatting HIV and AIDS (CACHA) & National AIDS Authority. (2009). Research Report: Policies environment regarding universal access and the right to work of Entertainment Workers in Cambodia.  At: http://www.hacccambodia.org/download_pub.php?file=CACHA%20Action%20Research%20final_English%20version.pdf

Chhoeurng, Rachana; Kong, Yara; Power, Erin. (2016). Poverty of LGBT people in Cambodia. London, UK: Micro Rainbow International C.I.C. At: https://microrainbow.org/wp-content/uploads/2017/12/CambodiaReportEN.pdf

Micro Rainbow International (MRIF) (2018). A wave of LGBTI acceptance in Cambodia. At: https://mrifoundation.global/a-wave-of-lgbti-acceptance-in-cambodia/

National AIDS Authority, (NAA). (2010). National Strategic Plan for a Comprehensive and Multi-sectoral Response to AIDS for 2011-2015. At: https://www.ilo.org/wcmsp5/groups/public/---ed_protect/---protrav/---ilo_aids/documents/legaldocument/wcms_177742.pdf

Kunthear, M and Drennan, J. (2013) Laws can't stop lovers Marrying. Phnom Penh Post, 20 May 2013. At: https://www.phnompenhpost.com/national/laws-can%E2%80%99t-stop-lovers-marrying

RoCK. (2019). Family Violence towards Lesbian, Bisexual and Transgender (LBT) People in Cambodia t. At: http://www.suarakita.org/wp-content/uploads/2019/07/Family-Violence-towards-Lesbian-Bisexual-and-Transgender-LBT-People-in-Cambodia-Report.pdf

RoCK, MRIF. (2019). Second National Dialogue on Legal and Public Policies to Protect LGBTIQ People in Cambodia. Joint Press Release. 27 June 2019. Phnom Penh. At: https://cchrcambodia.org/media/files/press_release/716_fprpde_en.pdf?fbclid=IwAR1EXzAMx6-oofncSAus0xfkOMrbig8EkmYewNUBsLbpYefl-L_YQsAJRxc

Salas V & Srun S. (2013). An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities and their ways of coping. Research report. Social Protection Coordination Unit, Council for Agricultural Research and Development (SPCU-CARD), Phnom Penh.

The World Bank (2005). Country Assessment Strategy (CAS) for the Kingdom of Cambodia
The World Bank. Sexual Orientation and Gender Identity. At: https://www.worldbank.org/en/topic/sexual-orientation-and-gender-identity

UNDP, USAID (2014). Being LGBTI in Asia: Cambodia Country Report. Bangkok. At: https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf

UNESCO (2008). HIV/AIDS Prevention Programme: Ethnography of Male to Male Sexuality in Cambodia. Phnom Penh. At http://unesdoc.unesco.org/images/0016/001630/163077E.pdf

Oxford Poverty and Human Development Initiative (2018). Global Multidimensional Poverty Index 2018: The Most Detailed Picture to Date of the World's Poorest People. University of Oxford, UK. At: https://ophi.org.uk/multidimensional-poverty-index/global-mpi-2018/

United Nations Human Rights Council. (2019). Universal Periodic Review (UPR), (Third Cycle), 2019: Cambodia. Matrix of recommendations (English). At https://www.ohchr.org/EN/HRBodies/UPR/Pages/KHindex.aspx

Yogyakarta Principles Plus 10 (YP+10) At: https://yogyakartaprinciples.org/principles-en/yp10/T

អ្នកអាចស្វែងរករបាយការណ៍នេះទាំងភាសាខ្មែរ និងអង់គ្លេសតាមរយៈគេហទំព័រ៖
www.mrifoundation.global

You can find full research report both English and Khmer at:
www.mrifoundation.global

The Green House 244-254 Cambridge Heath Road London E2 9DA,
United Kingdom | info@mrifoundation.global
Micro Rainbow International Foundation is a registered charity in
England and Wales (no 1169868)